技能実習生手帳

សៀវភៅសម្រាប់កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ

カンボジア語版

(ការបោះពុម្ពផ្សាយជាភាសាខ្មែរ)

外国人技能実習機構

អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស

OTIT

អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេសទូរស័ព្ទទំនាក់ទំនងពិគ្រោះយោបល់ជាភាសាកំណើត

- នៅពេលអ្នកមានអារម្មណ៍កង្វល់ក្នុងចិត្តឬព្រួយបារម្ភក្នុងការងារឬក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- នៅពេលអ្នកមានអារម្មណ៍ថានៅកន្លែងហ្វឹកហ្វឺនជំនាញមានការរំលោភបំពានលើប្រាក់ឈ្នួលឬការងារក្រៅ(បន្ថែម)ម៉ោង។ ល។
- ក្នុងករណីត្រូវគេបង្ខំអោយវិលត្រឡប់ទៅស្រុកវិញ ផ្ទុយពីឆន្ទៈរបស់អ្នក
- នៅពេលអ្នកមិនដឹងពីទីកន្លែងទំនាក់ទំនង សុំពិគ្រោះពីច្បាប់ឬប្រព័ន្ធនានារបស់ប្រទេសជប៉ុន ជាដើម

មន្ត្រីពិគ្រោះយោបល់នឹងឆ្លើយតបជាភាសាកំណើតជូនដល់អ្នក! (ឥតគិតថ្លៃ)

ភាសាវៀតណាម	ច័ន្ទសុក្រ	11:00~19:00	TEL: 0120-250-168
	ថ្ងៃអាទិត្យ	9:00~17:00	
ភាសាចិន	ច័ន្ទ • ពុធ • សុក្រ	11:00~19:00	TEL: 0120-250-169
	ថ្ងៃអាទិត្យ	9:00~17:00	
ភាសាឥណ្ឌូណេស៊ី	អង្គារ • ព្រហស្បត្តិ៍	11:00~19:00	TEL: 0120-250-192
ភាសាហ្វីលីពីន	អង្គារ • សៅរ៍	11:00~19:00	TEL: 0120-250-197
ភាសាអង់គ្លេស	អង្គារ • សៅរ៍	11:00~19:00	TEL: 0120-250-147
ភាសាថៃ	ព្រហស្បត្តិ៍ • សៅរ៍	11:00~19:00	TEL: 0120-250-198
ភាសាខ្មែរ	ព្រហស្បត្តិ៍	11:00~19:00	TEL: 0120-250-366
ភាសាមីយ៉ាន់ម៉ា	សុក្រ	11:00~19:00	TEL: 0120-250-302

ចំពោះព័ត៌មានលំអិត សូមមើលទំព័រ30ឬគេហទំព័ររបស់អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស។(https://www.otit.go.jp)ហើយ នៅទំព័រចុងក្រោយមានសេចក្តីណែនាំស្តីអំពីទូរស័ព្ទទំនាក់ទំនងពិគ្រោះយោបល់ជាភាសាកំណើត សូមកាត់តាមខ្សែរបន្ទាត់ ហើយសូមដាក់(តាមខ្លួន)នៅក្នុងកាបូបលុយជាដើម។

<គេហទំព័រពិគ្រោះយោបល់ជាភាសាកំណើត>

មជ្ឈមណ្ឌលព័ត៌មានទូទៅស្តីអំពីការស្នាក់នៅជនបរទេស

ចំពោះការពិគ្រោះយោបល់ស្តីអំពីនិតិវិធី(ឬការបំពេញបែបបទ)អន្តោប្រវេសន៍ សូមទំនាក់ទំនងតាមលេខទូរស័ព្ទខាងក្រោមនេះ។

ទូរស័ព្ទលេខ:	0570-013904
	03-5796-7112 (តាម IP • PHS • ក្រៅប្រទេស)
អាចទំនាក់ទំនងបានតាមរយៈ:	ភាសាជប៉ុន, អង់គ្លេស, ចិន, កូរ៉េ, អេស្ប៉ាញ, ព័រទុយហ្គាល់
អ៊ីមែល:	info-tokyo@i.moj.go.jp
រៀងរាល់សប្តាហ៍:	ច័ន្ទ～សុក្រ 8:30～17:15

外国人技能実習機構　母国語相談ホットライン

・仕事上や日常生活で悩みや不安を感じたとき
・賃金や時間外労働等について実習先で違反があると感じたとき
・意に反して帰国させられそうなとき
・日本の法律、各種制度に関して相談先が分からないとき　など

相談員がみなさんの母国語で対応します！（無料）

ベトナム語	月曜～金曜	11:00～ 19:00	TEL: 0120-250-168
	日曜	9:00～ 17:00	
中国語	月曜・水曜・金曜	11:00～ 19:00	TEL: 0120-250-169
	日曜	9:00～ 17:00	
インドネシア語	火曜・木曜	11:00～ 19:00	TEL: 0120-250-192
フィリピン語	火曜・土曜	11:00～ 19:00	TEL: 0120-250-197
英語	火曜・土曜	11:00～ 19:00	TEL: 0120-250-147
タイ語	木曜・土曜	11:00～ 19:00	TEL: 0120-250-198
カンボジア語	木曜	11:00～ 19:00	TEL: 0120-250-366
ミャンマー語	金曜	11:00～ 19:00	TEL: 0120-250-302

詳しくは31ページ、外国人技能実習機構HP（https://www.otit.go.jp）を見てください。また、最終ページの母国語相談ホットラインの案内を、点線に沿って切り取って、パスケース等に入れておいてください。

＜母国語相談サイト＞

外国人在留総合インフォメーションセンター

入国在留手続に関する相談は、下記をご利用ください。

電話:　0570-013904
　　03-5796-7112（IP・PHS・海外から）
対応言語:　日本語、英語、中国語、韓国語、スペイン語、ポルトガル語
Eメール:　info-tokyo@i.moj.go.jp
毎週:　月～金　8:30～ 17:15

技能実習生手帳（カンボジア語版）

សៀវភៅកម្មសិក្សាការបច្ចេកទេសជំនាញ (ការបោះពុម្ពផ្សាយជាភាសាខ្មែរ)

所有者（技能実習生氏名）／កម្មសិទ្ធិករ (ឈ្មោះកម្មសិក្សាការហ្វឹកហ្វឺនជំនាញ)
氏名／ឈ្មោះ

監理団体／អង្គភាពគ្រប់គ្រង
名称・住所・連絡先／ឈ្មោះអង្គភាព , អាសយដ្ឋាន , លេខទំនាក់ទំនង
《相談員》氏名・連絡先／ អ្នកប្រឹក្សា : ឈ្មោះ , លេខទំនាក់ទំនង

実習実施者／អ្នកអនុវត្តការហ្វឹកហ្វឺនជំនាញ
名称・住所・連絡先／ឈ្មោះអង្គភាព , អាសយដ្ឋាន , លេខទំនាក់ទំនង
《相談員》氏名・連絡先／អ្នកប្រឹក្សា : ឈ្មោះ , លេខទំនាក់ទំនង

外国人技能実習機構(OTIT)HP（https://www.otit.go.jp/）
អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស (OTIT) គេហទំព័រ (https://www.otit.go.jp/)

មាតិកា

1. អារម្ភកថា 8
2. របបហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស 8
3. ការស្រាវជ្រាវតាមដាន 12
4. ស្តីពីច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ 14
5. អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស គឺជា 16
6. ស្តីពីភារកិច្ចនៃកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ 18
7. ស្តីពីសោហ៊ុយដែលបង់ឱ្យស្ថាប័នបញ្ជូន ជាអាទិ៍ មុនមកជប៉ុន 18
(ស្តីពីទំនាក់ទំនងមិនត្រឹមត្រូវរវាងអង្គភាពគ្រប់គ្រង និង ស្ថាប័នបញ្ជូន)
8. ការត្រៀមចិត្តសម្រាប់ការហ្វឹកហ្វឺនជំនាញ 20
9. ការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្តិ ជាអាទិ៍ 22
10. ប័ណ្ណស្នាក់នៅ 26
11. ក្នុងករណីដែលមានការលំបាកក្នុងការហ្វឹកហ្វឺនជំនាញ 28
12. ក្នុងករណីរៀបអាពាហ៍ពិពាហ៍មានផ្ទៃពោះសម្រាលកូននៅក្នុងកំឡុងពេលបំពេញហ្វឹកហ្វឺនជំនាញ 28
13. ការពិគ្រោះក្នុងអង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស [ការពិភាក្សាជា ភាសាកំណើត] 30
14. ស្តីពី "សេចក្តីរាយការណ៍" ដែលលោកអ្នកអាចធ្វើបាន 34
(1) សេចក្តីរាយការណ៍ដោយផ្អែកលើច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ 34
(2) ការរាយការណ៍ដែលយោងតាមច្បាប់ស្តីពីស្តង់ដារការងារជាដើម 36
15. អ្វីដែលទាក់ទងនឹងច្បាប់ទាក់ទងនឹងការងារ 38
(1) កិច្ចសន្យាការងារ 38
(2) ម៉ោងធ្វើការនិងការសម្រាក • ថ្ងៃឈប់សម្រាក 40
(3) ថ្ងៃឈប់សម្រាក់ប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល 42
(4) ប្រាក់ឈ្នួល 42
16. សន្តិសុខសង្គម 46
(1) ប្រភេទការធានារ៉ាប់រងសង្គមនិងការផ្តល់ប្រាក់ 46
(2) បុគ្គលិកដែលជាមុខសញ្ញានៃសន្តិសុខសង្គម 46
(3) ថ្លៃបង់សន្តិសុខសង្គម 48
(4) នីតិវិធីទាមទារប្រាក់ដល់ដៃពេលចេញពីរបបសោធននិវត្តន៍និយោជិត ឬសោធននិវត្តន៍ជាតិ 48

目次

1．はじめに 9
2．外国人技能実習制度 9
3．フォローアップ調査 13
4．技能実習法について 15
5．外国人技能実習機構とは 17
6．技能実習生の責務について 19
7．入国前に送出機関等に支払う費用について 19
（監理団体と送出機関の不適切な関係について）
8．技能実習にあたっての心構え 21
9．法令の適用等 23
10. 在留カード 27
11. 技能実習を行うことが困難になった場合 29
12. 技能実習中に結婚・妊娠・出産などをした場合 29
13. 外国人技能実習機構における相談【母国語相談】 31
14. あなたがすることができる「申告」について 35
（1）技能実習法に基づく申告 35
（2）労働基準法等に基づく申告 37
15. 労働関係法令に関すること 39
（1）労働契約 39
（2）労働時間と休憩・休日 41
（3）年次有給休暇 43
（4）賃金 43
16. 社会保険 47
（1）社会保険の種類と給付 47
（2）社会保険の対象となる従業員 47
（3）社会保険料の額 49
（4）厚生年金、国民年金の脱退一時金の請求手続 49

17. ការធានារ៉ាប់រងការងារ 50
(1) ការធានារ៉ាប់រងរងគ្រោះមហន្តរាយ 50
(2) ការធានារ៉ាប់រងការងារ 52
18. ពន្ធប្រាក់ចំណូល ពន្ធប្រជាពលរដ្ឋ 52
19. ការពិនិត្យសុខភាព 56
20. ការការពារគ្រោះថ្នាក់ការងារក្នុងការហ្វឹកហ្វឺនជំនាញ 56
21. ជីវភាពនៅស្រុកជប៉ុន 62
22. ប្រព័ន្ធលេខអត្តសញ្ញាណបុគ្គល, ប័ណ្ណលេខអត្តសញ្ញាណបុគ្គល 72
23. ការពិភាក្សាគ្រប់ប្រភេទ.ច្រកទំនាក់ទំនងជំនួយ 76
i. ការពិគ្រោះអំពីលក្ខខ័ណ្ឌការងារជាដើម
(មន្ទីរការងារ និង មន្ទីរមន្ត្រីស្តង់ដារការងាររាជធានីនិងខេត្ត) 78
ii. ច្រកពិគ្រោះអំពីអំពីបែបបទចុះឈ្មោះស្នាក់នៅពេលចូលប្រទេស 84
iii. ច្រកទំនាក់ទំនងការពិភាក្សាសព្វបែបយ៉ាងឯទៀត 84

ឯកសារយោង

1. បញ្ជីទីលំនៅច្រកទំនាក់ទំនងការពិភាក្សា
តារាងទី១: អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស 92
តារាងទី២: កន្លែងពិគ្រោះទូទៅអំពីការងារ 94
តារាងទី៣: កន្លែងពិគ្រោះសម្រាប់កម្មករនិយោជិតបរទេស 98
តារាងទី៤: មន្ទីរគ្រប់គ្រងអន្តោប្រវេសន៍ 106
តារាងទី៥: ស្ថានទូតនិងស្ថានកុងស៊ុលនៃប្រទេសនីមួយៗ 108
2. លិខិតស្តីពីលក្ខខ័ណ្ឌការងារសម្រាប់ការហ្វឹកហ្វឺនជំនាញ 112
3. លំហូរនៃនីតិវិធីនៃការផ្តល់អត្ថប្រយោជន៍នៃការធានារ៉ាប់រងគ្រោះថ្នាក់ការងារ 120
4. លំហូរនៃនីតិវិធីទទួលប្រាក់ធានារ៉ាប់រងការងារ (ប្រាក់អត្ថប្រយោជន៍មូលដ្ឋាន) 124
5. តារាងប្រកាសដោយខ្លួនឯងចំពោះស្ថាប័នពេទ្យ និង ប័ណ្ណសំណូរជំនួយ 126
6. ភាសាជប៉ុនដែលប្រើគ្រាអាសន្ន 134
7. ផែនទីជប៉ុន 136
8. ឈ្មោះខេត្ត 137

17. 労働保険 51
（1）労災保険 51
（2）雇用保険 53
18. 所得税・住民税 53
19. 健康診断 57
20. 技能実習中の労働災害防止 57
21. 日本での生活 63
22. マイナンバー制度・マイナンバーカード 73
23. 各種相談・支援窓口 77
① 労働条件等の相談（都道府県労働局及び労働基準監督署） 79
② 入国在留手続に関する相談窓口 85
③ その他各種相談窓口 85

参考資料

１．相談窓口所在一覧
表１：外国人技能実習機構 93
表２：総合労働相談コーナー 95
表３：外国人労働者相談コーナー 99
表４：出入国在留管理局 107
表５：各国大使館・領事館 109
２．技能実習のための雇用条件書 112
３．労災保険給付手続の流れ 121
４．雇用保険（基本手当）受給手続の流れ 125
５．医療機関への自己申告表・補助問診票 127
６．緊急時に使う日本語 135
７．日本地図 136
８．都道府県名 137

1. អារម្ភកថា

សៀវភៅកម្មសិក្សាការីហ្វឹកហ្វឺនជំនាញបានប្រមូលពត៌មានដែលមានប្រយោជន៍សម្រាប់លោកអ្នកដែលជាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញអាចមានជីវភាពក្នុងការហ្វឹកហ្វឺនជំនាញដោយរក្សាសុខភាពនិងមានន័យខ្លឹមសារនៅស្រុកជប៉ុន។

អ្នកដែលជាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញនឹងបណ្តុះឲ្យមានជំនាញនិងបច្ចេកវិជ្ជាឬចំណេះផ្សេងៗ(ចាប់ពីទីនេះថា«ហ្វឹកហ្វឺនជំនាញជាដើម») ក្រោមកិច្ចសន្យាការងារក្នុងស្រុកជប៉ុន។

ក្នុងអំឡុងពេលនេះ ច្បាប់ស្រុកជប៉ុនជាច្រើនដែលទាក់ទងនឹងអ្នក។

ក្នុងសៀវភៅនេះ បានត្រូវកំណត់អ្វីដែលយើងបានរំពឹងថាជាពិសេសនិងសំខាន់និងអ្វីដែលត្រូវតែស្គាល់នៅពេលដែលរស់នៅស្រុកជប៉ុន ជាច្បាប់ដែលទាក់ទងនឹងអ្នក។

យើងសង្ឃឹមថាអ្នកនឹងប្រើសៀវភៅនេះយ៉ាងពេញលេញ ដើម្បីជួយឲ្យអ្នកមានជីវភាពដែលមានន័យខ្លឹមសារនៅស្រុកជប៉ុន។

2. របបហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស

គោលបំណងនៃ 〝របបហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស〞 គឺឲ្យកម្មករប្រទេសនានាៗទទួលបាននូវជំនាញជាអាទ៏ ពាក់ព័ន្ធនឹងឧស្សាហកម្មជាដើមរបស់ជប៉ុន ដើម្បីយកទៅប្រើក្នុងការអភិវឌ្ឍន៍ឧស្សាហកម្មនៃប្រទេសខ្លួន។

ការហ្វឹកហ្វឺនជំនាញរបស់លោកអ្នក ត្រូវបានធ្វើឡើងដោយផ្អែកលើផែនការហ្វឹកហ្វឺនជំនាញ ដែលធ្វើឡើងជាមុនដោយអ្នកអនុវត្តការហ្វឹកហ្វឺនជំនាញ។ ដើម្បីឱ្យទទួលបាននូវជំនាញជាអាទ៏ ដែលជាគោលដៅនៃផែនការនោះ លោកអ្នកត្រូវទទួលការហ្វឹកហ្វឺនជំនាញបណ្តើរពិចារណាបណ្តើរថា លោកអ្នកត្រូវធ្វើអ្វីខ្លះជារៀងរាល់ថ្ងៃ ។

ការចូលប្រទេស

ការហ្វឹកហ្វឺនជំនាញទី១	ឆ្នាំទី១	ការសិក្សា
		ការហ្វឹកហាត់
ការហ្វឹកហ្វឺនជំនាញទី២	ឆ្នាំទី២	ការហ្វឹកហាត់
	ឆ្នាំទី៣	

ការត្រឡប់ទៅប្រទេសវិញសិន

ការហ្វឹកហ្វឺនជំនាញទី៣	ឆ្នាំទី៤	ការហ្វឹកហាត់
	ឆ្នាំទី៥	

ការត្រឡប់ទៅប្រទេសវិញ

ដំណើរការនៃការហ្វឹកហ្វឺនជំនាញ

(ការហ្វឹកហ្វឺនជំនាញទី១)
- នៅក្រោយចូលប្រទេសមានការអង្គុយសិក្សា។
- សូមបណ្តុះឲ្យមានយ៉ាងយកចិត្តទុកដាក់អំពីជីវភាពនៅស្រុកជប៉ុននិងរបបហ្វឹកហ្វឺនជំនាញ។
- ក្រោយមក ការសិក្សានឹងចាប់ផ្តើមនៅក្រោមអ្នកអនុវត្តការហ្វឹកហ្វឺន។

*គោលដៅ: ជាប់ក្នុងការប្រឡងសមត្ថភាពជំនាញកម្រិតមូលដ្ឋាន (ប្រឡងវិញ្ញាសាអនុវត្តនិងទ្រឹស្តី)

(ការហ្វឹកហ្វឺនជំនាញទី២)
- សូមតំរង់ទៅឲ្យបច្ចេកទេសនំនាញជាដើមដែលបានរៀនក្នុងការហ្វឹកហ្វឺនជំនាញទី១ នោះកាន់តែល្អប្រសើរឡើងទៅទៀត។

*គោលដៅ: ជាប់ក្នុងការប្រឡងសមត្ថភាពជំនាញ កម្រិតទី៣ (ប្រឡងវិញ្ញាសាអនុវត្ត)

មុននឹងចូលទី៣ ឬ ក្នុងអំឡុងពេល១ឆ្នាំបន្ទាប់ពីបានចាប់ផ្តើមការហ្វឹកហ្វឺនជំនាញទី៣ គេតំរូវអោយអ្នកត្រឡប់ទៅប្រទេសខ្លួនវិញរយៈពេល១ខែឡើង។

(ការហ្វឹកហ្វឺនជំនាញទី៣)
- មានជំហានអនុវត្តតាមបច្ចេកទេសនំនាញជាដើមដែលបានរៀនក្នុងការហ្វឹកហ្វឺនជំនាញទី២។
- សូមបណ្តុះឲ្យមានបច្ចេកវិជ្ជាកាន់តែល្អប្រសើរឡើងទៀត។

*គោលដៅ: ជាប់ក្នុងការប្រឡងសមត្ថភាពជំនាញ កម្រិតទី២ (ប្រឡងវិញ្ញាសាអនុវត្ត)

(ក្រោយត្រឡប់ទៅប្រទេសវិញ)
សូមគាំទ្រការពិនិត្យដែលសម្រាប់បញ្ជាក់អ្វីដែលធ្វើរួចហើយ!
នៅក្រោយពីត្រឡប់ទៅប្រទេសវិញ បានត្រូវផ្ញើបណ្ណសំណួរដល់អ្នក ដូច្នេះ សូមរៀបរាប់អំពីស្ថានភាពចូលធ្វើការនិងការប្រើបច្ចេកទេសជំនាញ · បច្ចេកវិជ្ជា · ចំណេះដែលបានរៀននៅស្រុកជប៉ុន ។

1. はじめに

この技能実習生手帳は、技能実習生のみなさんが、日本において、健康で充実した技能実習生活を過ごすことができるように、あなたの役に立つ情報をまとめたものです。

技能実習生になったあなたは、日本国内で雇用契約のもとで様々な技能、技術又は知識（以下「技能等」という。）を身につけることとなります。この間あなたには、多くの日本の法律がかかわってきます。この手帳には、そういったあなたに関係する法律の中で、特に大切と思われるものや、日本で生活するに当たって、知っておかなくてはならないことが記載されています。

この手帳を十分に活用して、これからの日本での生活があなたにとって有意義ですばらしいものとなることを祈っています。

2. 外国人技能実習制度

外国人技能実習制度」は、諸外国の労働者に日本の産業等に関する技能等を修得してもらい、帰国後に修得した技能等を生かして、自国の産業の発展に活躍してもらうことを目的としているものです。
あなたの技能実習は、あらかじめ実習実施者で作成された技能実習計画に基づいて実施されます。あなたは、その計画に従って目標とする技能等を身につけるために、毎日何をすればいいか、しっかり考えながら技能実習に取り組みましょう。

入国

技能実習1号	1年目	講習
		実習
技能実習2号	2年目	実習
	3年目	

一旦帰国

技能実習3号	4年目	実習
	5年目	

帰国

技能実習の流れ

（技能実習1号）
・入国後に座学による講習があります。
・日本での生活や技能実習制度についてしっかり身につけましょう。
・その後、実習実施者の元で実習が始まります。
※目標：技能検定基礎級（実技・学科試験）合格

（技能実習2号）
・技能実習1号で修得した技能等の向上を目指しましょう。
※目標：技能検定3級（実技試験）合格

3号に移行する前、又は、技能実習３号を開始してから１年以内に1か月以上帰国する必要があります

（技能実習3号）
・技能実習2号で修得した技能等の応用段階となります。
・さらに技術をみがきましょう。
※目標：技能検定2級（実技試験）合格

（帰国後）
フォローアップ調査に協力してください！
帰国後にあなたのところにアンケート票が送られてきますので、帰国後の就職状況や日本で修得した技術・技能・知識の活用状況を教えてください。

* គោលដៅ

• ប្រភេទនៃការប្រឡងដែលជាគោលដៅនៃដំណាក់កាលនីមួយៗនៃការហ្វឹកហ្វឺនជំនាញនីមួយៗ។

ការហ្វឹកហ្វឺនជំនាញ	ការប្រឡងសមត្ថភាពជំនាញដែលជាគោលដៅ	កម្រិតនៃជំនាញនិងចំណេះដឹងដែលត្រូវការ
ទី១	ប្រឡងសមត្ថភាពជំនាញ កម្រិតមូលដ្ឋាន (ឬប្រឡងវាយតម្លៃនៃការហ្វឹកហ្វឺនជំនាញកម្រិតបឋម)	ជំនាញ · ចំណេះមូលដ្ឋានដែលត្រូវការដើម្បីបំពេញការងារមូលដ្ឋាន។
ទី២	ប្រឡងសមត្ថភាពជំនាញ កម្រិតទី៣ (ឬប្រឡងវាយតម្លៃនៃការហ្វឹកហ្វឺនជំនាញកម្រិតឯកទេស)	ជំនាញ · ចំណេះដែលកម្មករដែលមានជំនាញកម្រិតបឋមត្រូវមានជាធម្មតា។
ទី៣	ប្រឡងសមត្ថភាពជំនាញ កម្រិតទី២ (ឬប្រឡងវាយតម្លៃនៃការហ្វឹកហ្វឺនជំនាញកម្រិតខ្ពស់)	ជំនាញចំណេះដឹងដែលកម្មករដែលមានជំនាញកម្រិតមធ្យមត្រូវមានជាធម្មតា។

ដើម្បីអ្នកធ្វើការហ្វឹកហ្វឺនជំនាញទី២ឬការហ្វឹកហ្វឺនជំនាញទី៣ ត្រូវតែជាប់ប្រឡងដែលបានកំណត់ទុកជាមុនដែលជាគោលដៅការទៅដល់នៃដំបានមុន។ទោះជាមិនបានជាប់ប្រឡងក្តី មានឱកាសម្តងទៀត ដូច្នេះ សូមប្រឹងធ្វើការហ្វឹកហ្វឺនជំនាញជារៀងរាល់ថ្ងៃដោយសំដៅទៅដល់គោលដៅ។

(1) ឆ្នាំទី១នៃការហ្វឹកហ្វឺនជំនាញ "ការហ្វឹកហ្វឺនជំនាញទី១"

ក្នុងការហ្វឹកហ្វឺនជំនាញទី១ ជាបឋម មានការសិក្សាមេរៀន ក្រោយពេលមកដល់ប្រទេសជប៉ុន។ ក្នុងមេរៀននេះ ត្រូវសិក្សាជាភាសាជប៉ុន អំពីចំណេះដឹងដែលចាំបាច់ដើម្បីហ្វឹកហ្វឺនជំនាញ។

ខ្លឹមសារសំអិតនៃមេរៀននោះមានដូចតទៅ។

• ភាសាជប៉ុន
• ចំណេះដឹងស្តីពីជីវភាពទូទៅនៅប្រទេសជប៉ុន
• ចំណេះដឹងស្តីពីច្បាប់ដែលចាំបាច់សម្រាប់ការហ្វឹកហ្វឺនជំនាញ
• ចំណេះដឹងដែលចាំបាច់ទទួលបានក្នុងការសិក្សាជំនាញ

បន្ទាប់មក ត្រូវសិក្សាជំនាញជាអាទិ៍ ក្រោមកិច្ចសន្យាការងារជាមួយនឹងអ្នកអនុវត្តការហ្វឹកហ្វឺនជំនាញ។

ក្នុងករណីដែលមានគម្រោងនឹងប្តូរទៅការហ្វឹកហ្វឺនជំនាញទី២ ត្រូវតែប្រឡងសមត្ថភាពជំនាញ (ឬប្រឡងដើម្បីវាយតម្លៃការហ្វឹកហ្វឺនជំនាញ) ដែលមានវិញ្ញាសាអនុវត្ត និងវិញ្ញាសាទ្រឹស្តី ហេតុនេះហើយ ត្រូវលើកយកគោលដៅប្រឡងជាប់កម្រិតមូលដ្ឋាន (ឬកម្រិតបឋម)។

(2) ឆ្នាំទី២ ឆ្នាំទី៣ នៃការហ្វឹកហ្វឺនជំនាញ "ការហ្វឹកហ្វឺនជំនាញទី២"

នៅក្នុងការហ្វឹកហ្វឺនជំនាញទី២ ដើម្បីទទួលបាននូវជំនាញដ៏ស្ទាត់បន្ថែមទៀតជាអាទិ៍ (ឱ្យជាប់ក្នុងខ្លួន)ដែលទទួលបានក្នុងការហ្វឹកហ្វឺនជំនាញទី១ ជាគោលការណ៍ គឺត្រូវហ្វឹកហ្វឺនជំនាញបន្តទៀត ជាមួយនឹងអ្នកអនុវត្តការហ្វឹកហ្វឺនជំនាញ(ក្រុមហ៊ុន)ដដែល។

ពេលបញ្ចប់ការហ្វឹកហ្វឺនជំនាញទី២ ត្រូវតែប្រឡងសមត្ថភាពជំនាញ (ឬប្រឡងដើម្បីវាយតម្លៃការហ្វឹកហ្វឺនជំនាញ) ដែលមានវិញ្ញាសាអនុវត្ត ហេតុនេះហើយ ត្រូវលើកយកគោលដៅប្រឡងជាប់កម្រិតអនុវត្តនៃកម្រិតទី៣ (ឬកម្រិតឯកទេស)។

(3) ឆ្នាំទី៤ ឆ្នាំទី៥នៃការហ្វឹកហ្វឺនជំនាញ "ការហ្វឹកហ្វឺនជំនាញទី៣"

ការហ្វឹកហ្វឺនជំនាញទី៣ គឺជាដំណាក់កាលហ្វឹកហ្វឺនឱ្យកាន់តែស្ទាត់ថែមទៀតនូវជំនាញដែលបានទទួលក្នុងការហ្វឹកហ្វឺនជំនាញទី២ ដូច្នេះត្រូវទទួលការហ្វឹកហ្វឺនជំនាញនៅអង្គភាពគ្រប់គ្រងនិងអ្នកអនុវត្តការហ្វឹកហ្វឺនដែលល្អប្រសើរ។

ក្នុងករណីដែលប្តូរពីការហ្វឹកហ្វឺនជំនាញទី១ ទៅការហ្វឹកហ្វឺនជំនាញទី២ ជាគោលការណ៍ ត្រូវហ្វឹកហ្វឺនបន្តជាមួយនឹងអ្នកអនុវត្តការហ្វឹកហ្វឺនដដែល ប៉ុន្តែក្នុងករណីដែលប្តូរទៅការហ្វឹកហ្វឺនជំនាញទី៣ មិនមានការកម្រិតឱ្យទទួលតែការហ្វឹកហ្វឺនជាមួយនឹងអ្នកអនុវត្តការហ្វឹកហ្វឺនហូតដល់ការហ្វឹកហ្វឺនទី២នោះទេ គឺកម្មសិក្សាការហ្វឹកហ្វឺនជំនាញអាចជ្រើសរើសអ្នកអនុវត្តការហ្វឹកហ្វឺនជំនាញដោយខ្លួនឯងបាន។

ម្យ៉ាងទៀត ក្នុងករណីប្តូរទៅការហ្វឹកហ្វឺនជំនាញទី៣, មុននឹងចាប់ផ្តើមការហ្វឹកហ្វឺនជំនាញទី៣ ឬ ក្នុងអំឡុងពេល១ឆ្នាំបន្ទាប់ពីបានចាប់ផ្តើមការហ្វឹកហ្វឺនជំនាញទី៣ គេតំរូវអោយអ្នកត្រឡប់ទៅប្រទេសខ្លួនវិញរយៈពេល១ខែឡើង។ ពេលអ្នកប្តូរទៅការហ្វឹកហ្វឺនជំនាញទី៣ អ្នកត្រូវឈ្លតចេញពីប្រទេសកំណើតរបស់អ្នករយៈពេលយ៉ាងយូរ៥ឆ្នាំ ដូច្នេះហើយ សូមភ្ជាប់ទំនាក់ទំនងនឹងប្រទេសកំណើតរបស់អ្នក ដូចជាការជួបជាមួយនឹងក្រុមគ្រួសារជាដើម។

ពេលបញ្ចប់ការហ្វឹកហ្វឺនជំនាញទី៣ ត្រូវតែប្រឡងសមត្ថភាពជំនាញ (ឬប្រឡងដើម្បីវាយតម្លៃការហ្វឹកហ្វឺនជំនាញ) ដែលមានវិញ្ញាសាអនុវត្ត ហេតុនេះហើយ ត្រូវលើកយកគោលដៅប្រឡងជាប់កម្រិតអនុវត្តនៃកម្រិតទី២ (ឬកម្រិតខ្ពស់)។

ក្នុងករណីដែលប្តូរអ្នកអនុវត្តការហ្វឹកហ្វឺន(ក្រុមហ៊ុន)ក្នុងការហ្វឹនហ្វឺនជំនាញទី៣ ត្រូវធ្វើនីតិវិធីស្វែងរកការងារគោមអង្គភាពគ្រប់គ្រង ប៉ុន្តែបើសិនជាមានអ្វីមិនយល់ច្បាស់ទេ សូមមកពិគ្រោះជាមួយនឹងអង្គការ(OTIT)ឬពិគ្រោះយោបល់ជាភាសាកំណើត។ ម្យ៉ាងទៀត កំមានការណែនាំនៅក្នុងគេហទំព័ររបស់អង្គការយើងខ្ញុំ ដូច្នេះសូមលោកអ្នកចូលមើលផង។

(4) ការផ្លាស់ប្តូរទៅ "ជំនាញពិសេសទី១"

ចំពោះកម្មសិក្សាការហ្វឹកហ្វឺនជំនាញដែលបានបញ្ចប់ការហ្វឹកហ្វឺនជំនាញទី២បានល្អ ពេលផ្លាស់ប្តូរទៅជំនាញពិសេសទី១ គេអនុគ្រោះមិនចាំបាច់ប្រឡងជំនាញ ឬប្រឡងសមត្ថភាពភាសាជប៉ុន។

ជំនាញពិសេសទី១ គឺជាលក្ខណៈសម្បត្តិមួយនៃការស្នាក់នៅដើម្បីធ្វើការនៅប្រទេសជប៉ុន ដែលត្រូវបានចាប់ផ្តើមពីខែមេសា ឆ្នាំ 2019។

※目標

・各技能実習の段階で目標にする検定試験の種類です。

技能実習	目標とする検定試験	要求される技能・知識の水準
1号	技能検定基礎級 （又は技能実習評価試験初級）	基本的な業務を遂行するために必要な基礎的な技能・知識
2号	技能検定3級 （又は技能実習評価試験専門級）	初級の技能労働者が通常有すべき技能・知識
3号	技能検定2級 （又は技能実習評価試験上級）	中級の技能労働者が通常有すべき技能・知識

あなたが技能実習2号又は技能実習3号を行うためには、前段階の到達目標としてあらかじめ定めた検定試験に合格しなければなりません。試験に一度失敗しても、もう一度チャンスがあるので目標に向かって、日々、技能実習に取り組みましょう。

(1) 技能実習1年目 「技能実習1号」

技能実習1号においては、まず、入国後の講習があります。講習では日本で技能実習を行うために必要な知識を学んでいただきます。

具体的な講習の内容は、以下のとおりです。

・日本語
・日本での生活一般に関する知識
・技能実習を行う上で必要な法律の知識
・技能を修得する上で必要な知識

その後、実習実施者との雇用契約の下で技能等の修得を行います。

技能実習2号に移行する予定がある場合は、技能検定（又は技能実習評価試験）の実技試験と学科試験の受検が必須で、基礎級（又は初級）への合格を目標としなければなりません。

(2) 技能実習2年目、3年目 「技能実習2号」

技能実習２号においては、技能実習１号で修得した技能等をさらに習熟（身につける）するために、原則として同じ実習実施者において、引き続き技能等を修得します。

技能実習2号の修了時において、技能検定（又は技能実習評価試験）の実技試験の受検が必須で、3級（又は専門級）の実技試験への合格を目標としなければなりません。

(3) 技能実習4年目、5年目 「技能実習3号」

技能実習3号は、技能実習2号で身につけた技能等に熟達するための段階となり、優良な監理団体及び実習実施者のもとで技能実習を行うことになります。

技能実習1号から技能実習2号に移行する場合は、原則として同じ実習実施者のもとで技能実習を継続しなければなりませんが、技能実習3号に移行する場合は、技能実習2号までの実習実施者に限定されず、技能実習生自身が実習実施者を選ぶことが可能となります。

また、技能実習３号に移行する場合は、技能実習１号開始前、又は、技能実習３号開始後１年以内に必ず一か月以上帰国しなければなりません。技能実習3号に移行した際は、最長5年間母国から離れることになりますので、家族と会うなど母国とのつながりを再確認してください。

技能実習3号の修了時において、技能検定（又は技能実習評価試験）の実技試験の受験が必須で、2級（又は上級）への合格を目標としなければなりません。

技能実習３号において実習実施者を変更する場合は、監理団体に求職の手続を行うこととなりますが、分からないことがあれば、機構又は母国語相談に気軽に相談してください。また、機構のホームページでも案内していますので併せてチェックしてください。

(4)「特定技能1号」への移行

技能実習2号を良好に修了した技能実習生は、特定技能1号への移行にあたって、技能試験や日本語能力試験が免除されます。

特定技能1号とは、2019年4月に始まった日本で働くための在留資格の1つです。

3. ការស្រាវជ្រាវតាមដាន

សូមសហការក្នុងការស្រាវជ្រាវតាមដាន

អង្គការយើងខ្ញុំធ្វើ "ការស្រាវជ្រាវតាមដានកម្មសិក្សាការីហ្វឹកហ្វឺនជំនាញដែលបានត្រឡប់ទៅវិញ" ចំពោះកម្មសិក្សាការីដែលបានត្រឡប់ទៅប្រទេសខ្លួនវិញបន្ទាប់ពីបានបញ្ចប់ការហ្វឹកហ្វឺនជំនាញ ក្នុងគោលបំណងភ្ជាប់នូវស្ថានភាពនៃការធ្វើការងារក្រោយពេលត្រឡប់ទៅប្រទេសខ្លួនវិញ ឬស្ថានភាពនៃការហ្វឹកហ្វឺនជំនាញនៅប្រទេសជប៉ុន។

ដើម្បីធ្វើឱ្យរបបហ្វឹកហ្វឺនជំនាញនេះកាន់តែល្អនេះគឺជាការសិក្សាស្រាវជ្រាវដ៏សំខាន់ តាមរយៈការសួរមតិយោបល់ពីកម្មសិក្សាការីហ្វឹកហ្វឺនជំនាញដែលបានបញ្ចប់ការសិក្សានៅជប៉ុន ហើយត្រឡប់ទៅប្រទេសខ្លួនវិញ។

ក្នុងករណីដែលមុនពេលត្រឡប់ទៅប្រទេសខ្លួនវិញ អង្គភាពគ្រប់គ្រង ឬអ្នកអនុវត្តការហ្វឹកហ្វឺនជំនាញបានឱ្យប័ណ្ណអង្កេតហើយនៅពេលត្រឡប់ទៅប្រទេសខ្លួនវិញ សូម Log In ចូលទំព័រចម្លើយតាមអនឡាញ ដោយប្រើ ID និងពាក្យសម្ងាត់ ហើយឆ្លើយតាមអក្រង់អង្កេតតាមអនឡាញ ឬក៏បំពេញប័ណ្ណក្រដាសអង្កេតដោយខ្លួនឯង ហើយដាក់ក្នុងស្រោមសំបុត្រដែលបានភ្ជាប់ជាមួយ ហើយដាក់តាមបុស្តិ៍ប្រៃសនីយ៍មកយើងខ្ញុំ។

អង្គភាពរបស់លោកអ្នក មានសារៈសំខាន់ណាស់សម្រាប់កម្មសិក្សាការីហ្វឹកហ្វឺនជំនាញនៅជប៉ុន ដូច្នេះសូមសហការ។

ករណីឆ្លើយតាមអនឡាញ

- ក្រោយពេលត្រឡប់ទៅប្រទេសខ្លួនវិញ សូមLog In ចូលទំព័រចម្លើយតាមអនឡាញ ដោយប្រើ ID និងពាក្យសម្ងាត់ដែលបានចែកជូនម្នាក់ៗ។
- សូមឆ្លើយដោយខ្លួនឯងតាមអក្រង់នៃប័ណ្ណអង្កេតដែលបានបង្ហាញក្នុងទំព័រចម្លើយ។
- អាចឆ្លើយនឹងសំណួរបានតាមរយៈការគ្លិកទៅលើសំណួរ ជាអាទិ៍។

ករណីឆ្លើយហើយផ្ញើតាមប្រៃសនីយ៍

- ក្រោយពេលត្រឡប់ទៅប្រទេសខ្លួនវិញ សូមបំពេញប័ណ្ណអង្កេតដោយខ្លួនឯង។
- ដាក់ប័ណ្ណអង្កេតនោះចូលក្នុងស្រោមសំបុត្រដែលបានជូនភ្ជាប់ជាមួយ ហើយដាក់តាមបុស្តិ៍ប្រៃសនីយ៍។
- ពេលដាក់បុស្តិ៍ប្រៃសនីយ៍ មិនចាំបាច់ចិទតែមប្រ៉ូទេ។



សេចក្តីសង្ខេបពីលទ្ធិផលនៃការពិនិត្យការប្រព្រឹត្តតាមកម្មសិក្សាការីហ្វឹកហ្វឺនជំនាញដែលត្រឡប់ទៅប្រទេសវិញប្រចាំឆ្នាំ២០១៨

- អ្នកដែលឆ្លើយតបថា "មានប្រយោជន៍"អំពីអ្វីដែលបានរៀនក្នុងកំឡុងពេលហ្វឹកហ្វឺនជំនាញគឺ98.2%។
- ខ្លឹមសារលំអិតនៃអ្វីៗដែលមានប្រយោជន៍គឺ "ទទួលបាននូវបច្ចេកទេសជំនាញ" មាន 75.3% ដែលខ្ពស់ជាងគេ បន្ទាប់មកគឺ "បទពិសោធន៍នៃជីវភាពរស់នៅ។ជប៉ុន" មាន 68.5% បន្ទាប់មកទៀតគឺ "ទទួលបាននូវចំណេះដឹងភាសាជប៉ុន" មាន 68.3%។
- ស្តីអំពីស្ថានភាពការងារបន្ទាប់ពីត្រឡប់ទៅប្រទេសវិញ នៅក្នុងនោះមានដូចជា"ត្រូវបានគេទទួលឲ្យធ្វើការ(22.2%)", "ត្រូវបានគេទទួលឲ្យធ្វើការដោយបានសម្រេចចិត្តធ្វើការ (9.1%)", "បង្កើតអជីវកម្មខ្លួនឯង(15.0%)"គឺអ្នកដែលបានឆ្លើយតបមានចំនួនសរុប46.2%។
  ម៉្យាងទៀត បន្ទាប់ពីត្រឡប់ទៅប្រទេសវិញ អ្នកដែលឆ្លើយថា"កំពុងរកការងារធ្វើ"គឺ25.3%។
- ព័ត៌មានលម្អិតនៃការងារដែលកម្មសិក្សាការីបានធ្វើ មានចំនួន68.0%។បានឆ្លើយតបថា"ធ្វើការងារដូចដែលបានការសិក្សាគឺ(48.2%)"ហើយ"ធ្វើការងារដូចនឹងជំនាញដែលបានសិក្សារ(19.8%)"

3. フォローアップ調査

フォローアップ調査にご協力ください

機構では、技能実習を終えて帰国する技能実習生の方を対象に、帰国後の就職状況や日本での技能実習の実態を把握することを目的として「帰国後技能実習生のフォローアップ調査」を行います。

今後の技能実習制度をより良いものにするために、技能実習を修了して帰国する技能実習生の方のご意見を伺うもので、とても大切な調査です。

帰国前に監理団体や実習実施者からアンケート調査票を渡された場合は、帰国後にIDとパスワードを使用してオンライン調査画面にログインし、調査画面から自分で入力して回答するか、紙の調査票に自分で記入した上で同封の返信用封筒に入れて投函するか、どちらかをお選びください。

あなたのアンケートは日本で技能実習を行う技能実習生にとって役に立つものです。是非ご協力をお願いします。

オンラインにより回答する場合

- 帰国後に、それぞれに割り振られたIDとパスワードを使用してオンライン調査画面にログインしてください
- 回答ページに表示された調査票の画面から自分で回答してください
- 設問をクリックする等により、回答ができます

郵送により回答する場合

- 帰国後に、調査票を自分で記入してください
- 記入した調査票は、同封の返信用封筒に入れて投函してください
- 投函する際に切手を貼る必要はありません



2018年度の帰国技能実習生フォローアップ調査の結果概要

- 技能実習期間を通じて学んだことが「役に立った」と回答した人は98.2% となっている。
- 役に立った具体的な内容は、「修得した技能」の割合が75.3%と最も高く、「日本での生活経験」が68.5%、「日本語能力の修得」が68.3% と続く。
- 帰国後の就職状況について「雇用されて働いている(22.2%)」、「雇用されて働くことが決まっている(9.1%)」、「起業している(15.0%)」と回答した人の合計は46.2%となっている。また、帰国後「仕事を探している」と回答した人は25.3%となっている。
- 従事する仕事の内容は「実習と同じ仕事(48.2%)」または「実習と同種の仕事(19.8%)」と回答した人が、68.0%となっている。

4. ស្តីពីច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ

ឈ្មោះច្បាប់នេះជាផ្លូវការគឺ-ច្បាប់ស្តីពីការអនុវត្តឱ្យបានត្រឹមត្រូវនូវការហ្វឹកហ្វឺនជំនាញ និង ស្តីពីការការពារកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ (ខាងក្រោមនេះ ហៅកាត់ថា «ច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ»)។ (ប្រកាសជាសាធារណៈ: ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦, អនុវត្តពីថ្ងៃទី១ខែវិច្ឆិកា ឆ្នាំ២០១៧)

ច្បាប់នេះមានគោលបំណងអនុវត្តឱ្យបានត្រឹមត្រូវនូវការហ្វឹកហ្វឺនជំនាញ និង ការពារកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ហើយបានចែងអំពី i.ការកម្រិតដែលចាំបាច់ចំពោះអ្នកអនុវត្តការហ្វឹកហ្វឺន ឬអង្គភាពគ្រប់គ្រងដែលធ្វើការគ្រប់គ្រងការហ្វឹកហ្វឺនជំនាញនោះ ព្រមទាំងពង្រឹងប្រព័ន្ធត្រួតពិនិត្យការគ្រប់
គ្រងនោះ ii.ការចាត់វិធានការដោដើម ដើម្បីការពារកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ។ ព្រមជាមួយគ្នានេះ អ្នកអនុវត្តការហ្វឹកហ្វឺន ឬអង្គភាពគ្រប់គ្រងល្អ។ កំអាចអនុវត្តការហ្វឹកហ្វឺនជំនាញដែលមានកម្រិតខ្ពស់ដែរ។

[ការបកស្រាយ] សេចក្តីពន្យល់សង្ខេបអំពីច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ

- ការអនុវត្តឲ្យត្រឹមត្រូវនូវរបបហ្វឹកហ្វឺនជំនាញ · ការការពារកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ
  + កំណត់បាវចនាមូលដ្ឋានកម្មសិក្សាការីហ្វឹកហ្វឺនជំនាញឬការកិច្ចអ្នកដែលមានទំនាក់ទំនងជាមួយ ហើយត្រូវតែបង្កើតទិសដៅជាមូលដ្ឋានដែលទាក់ទងនឹងការហ្វឹកហ្វឺនជំនាញ។
  + អំពីកាលវិភាគការហ្វឹកហ្វឺនជំនាញដែលធ្វើសម្រាប់ប្រចាំកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ កំណាត់ថារបបដែលបញ្ជាក់ដោយបលិខិត ហើយកំណត់អំពីខ្លាតនាំការបញ្ជាក់ដោយលិខិតនិងមូលហេតុជាដើមដែលមិនជាប់ការបញ្ជាក់ដោយលិខិត បន្ថែមទៅទៀត កំណត់អំពីការយកបាយការណ៍របស់រដ្ឋមន្ត្រីដែលទទួលកិច្ចការ សេចក្តីបង្គាប់ដែលធ្វើឲ្យកាន់តែប្រសើរជាងទៅទៀត អំណាចដែលអាចលុបចោលការបញ្ជាក់ដោយលិខិតជាដើម។
  + អំពីអង្គភាពគ្រប់គ្រង កំណត់ថារបបដែលផ្តល់ការអនុញ្ញាត ហើយកំណត់ខ្លាតផ្តល់ការអនុញ្ញាតនិងមូលហេតុដែលមិនអាចទទួលការអនុញ្ញាត ម៉្យាងទៀតកំណត់អំពីប្រការអនុលោមតាម ការយកបាយការណ៍របស់រដ្ឋមន្ត្រីដែលទទួលកិច្ចការ សេចក្តីបង្គាប់ដែលធ្វើឲ្យកាន់តែប្រសើ អំណាចដែលអាចលុបចោលការបញ្ជាក់ដោយលិខិតជាដើម។
  + ដើម្បីជាវិធានការដែលទាក់ទងនឹងការការពារកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ បង្កើតវិន័យបម្រាមអំពីទង្វើដែលរំលោភសិទ្ធិមនុស្សជាដើមចំពោះកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ហើយកំណត់ពិន័យចំពោះល្មើសច្បាប់ បន្ថែមទៀត ឲ្យធ្វើការតម្រូវតាមការពិភាក្សាចំពោះកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ការផ្តល់ពត៌មាន ផ្តល់ជំនួយជាដើម។
- ការរីកឡើងនៃរបបហ្វឹកហ្វឺនជំនាញ
  + លុះត្រាតែអ្នកអនុវត្តការហ្វឹកហ្វឺន · អង្គភាពគ្រប់គ្រងល្អ។ អាចទទួលកម្មសិក្សាការីហ្វឹកហ្វឺនជំនាញទី៣(អនុវត្តការហ្វឹកហ្វឺនជំនាញនៅឆ្នាំទី៤ឬទី៥)

ជាពិសេស ស្តីពីការការពារកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ គេបានចែងដូចតទៅ។

- ស្តីពីទង្វើបំពានសិទ្ធិជាអាទិ៍ចំពោះកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ គេមានបញ្ញាត្តិហាម ហើយមានទណ្ឌកម្មបញ្ញត្តិផងដែរ។

[ការបកស្រាយ] ទង្វើបំពានសិទ្ធិចំពោះកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ

i. ទង្វើបង្ខំឱ្យហ្វឹកហ្វឺនជំនាញ
ii. ទង្វើកំណត់ប្រាក់សំណងពេលបំពានកិច្ចសន្យាជាអាទិ៍
iii. ទង្វើបង្កើតកិច្ចសន្យាគ្រប់គ្រងប្រាក់សន្សំ
iv. ទង្វើរក្សាទុកនូវលិខិតឆ្លងដែន ឬប័ណ្ណស្នាក់នៅ
v. ទង្វើកម្រិតសិទ្ធិសេរីភាពក្នុងជីវភាពរស់នៅឯកជនមិនត្រឹមត្រូវ

- ក្នុងករណីប្រាកដថាអ្នកអនុវត្តការហ្វឹកហ្វឺន(ក្រុមហ៊ុន)និងអង្គភាពគ្រប់គ្រងល្មើសច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ,បញ្ជាក់ឲ្យច្បាស់ថាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញអាចចាយការណ៍ទៅប្រធានមន្ទីរគ្រប់គ្រងអន្តោប្រវេសន៍ស្នាក់នៅនិងរដ្ឋមន្ត្រីសុខាភិបាលការងារនិងសុខុមាលភាពបាន។
  ការ។ម៉្យាងទៀតកំណត់ពិន័យចំពោះរបៀបប្រព្រឹត្តដែលបង្កើតផលអាក្រក់ដែលមានមូលហេតុជាសេចក្តីរាយការណ៍។
- ការតម្រូវតាមការពិភាក្សានិងការផ្តល់ពត៌មានចំពោះកម្មសិក្សាការីហ្វឹកហ្វឺនជំនាញក្នុងអង្គភាព ហើយធ្វើឡើងការផ្តល់ជំនួយជាដើម

4. 技能実習法について

この法律の正式な名称は「外国人の技能実習の適正な実施及び技能実習生の保護に関する法律」（以下「技能実習法」という。）〈公布：平成28年11月28日、施行：平成29年11月1日〉といいます。

この法律は、技能実習の適正な実施及び技能実習生の保護を図るため、①技能実習を実施する実習実施者やその実施を監理する監理団体に対して必要な規制を設け、管理監督体制を強化するとともに、②技能実習生の保護を図る措置などを定めています。併せて、優良な実習実施者や監理団体については、より高度な技能実習の実施を可能にしました。

【解説】技能実習法の概要

○技能実習制度の適正化・技能実習生の保護
- 技能実習生の基本理念及び関係者の責務を定めるとともに、技能実習に関し基本方針を策定すべきこと。
- 技能実習生ごとに作成する技能実習計画について、認定制とし、認定の基準や認定の欠格事由等を定めるほか、主務大臣の報告徴収、改善命令、認定の取消し等の権限を規定すること。
- 監理団体について、許可制とし、許可の基準や許可の欠格事由を定めるほか、遵守事項、主務大臣の報告徴収、改善命令、許可の取消し等の権限を規定すること。
- 技能実習生の保護に関する措置として、技能実習生に対する人権侵害行為等について、禁止規定を設け、違反に対する罰則を規定するとともに、技能実習生に対する相談対応や情報提供、援助等を行わせること。

○技能実習制度の拡充
- 優良な実習実施者・監理団体に限定して、第3号技能実習生の受入れ（4年目及び5年目の技能実習の実施）を可能とすること。

特に技能実習生の保護に関しては以下の通り定めています。
- 技能実習生に関する人権侵害行為等について禁止規定を設け、罰則を規定。

【解説】技能実習生に対する人権侵害行為

①技能実習を強制する行為
②違約金等を定める行為
③貯蓄金を管理する契約を締結する行為
④旅券・在留カードを保管する行為
⑤私生活の自由を不当に制限する行為

- 実習実施者や監理団体に技能実習法違反の事実がある場合、技能実習生は出入国在留管理庁長官及び厚生労働大臣に申告できることを明記。
  また、申告を理由とする不利益取扱に対する罰則も規定。
- 機構において技能実習生に対する相談対応や情報提供、援助等を実施。

5. អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស គឺជា

អង្គភាពជាក្រុមប្រឹក្សាសាជីវកម្មដែលផ្តល់សិទ្ធិអំណាចដែលបានត្រូវបង្កើតដោយក្រសួងយុត្តិធម៌និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានមូលដ្ឋានលើច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ។
អង្គភាពនឹងបំពេញអំណាចនិងតួនាទីដូចខាងក្រោមនេះ។



A: សិទ្ធិអំណាចរបស់អង្គការចំពោះអង្គភាពគ្រប់គ្រង
i. ធ្វើឡើងការពិនិត្យមើលប្រតិបត្តិចំពោះអង្គភាពគ្រប់គ្រង ការពិនិត្យមើលប្រតិបត្តិដោយទៀងទាត់/ការពិនិត្យមើលប្រតិបត្តិដែលមានមូលដ្ឋានសេចក្តីរាយការណ៍
ii. សុំរបាយការណ៍ពីអង្គភាពគ្រប់គ្រង

B: សិទ្ធិអំណាចរបស់អង្គការចំពោះអ្នកអនុវត្តការហ្វឹកហ្វឺន
i. កំណត់គម្រោងហ្វឹកហ្វឺនជំនាញ
ii. ធ្វើឡើងការពិនិត្យប្រតិបត្តិចំពោះអ្នកអនុវត្តការហ្វឹកហ្វឺនជំនាញ
ការពិនិត្យមើលប្រតិបត្តិដោយទៀងទាត់/ការពិនិត្យមើលប្រតិបត្តិដែលមានមូលដ្ឋានសេចក្តីរាយការណ៍
iii. សុំរបាយការណ៍ពីអ្នកអនុវត្តការហ្វឹកហ្វឺន
iv. ការព្រមទទួលប្រវេទន៍អ្នកអនុវត្តការហ្វឹកហ្វឺន

C: តួនាទីរបស់អង្គការចំពោះកម្មសិក្សាការហ្វឹកហ្វឺនជំនាញ
i. ការពិភាក្សាជាភាសាកំណើត · ការតម្រូវតាមសេចក្តីរាយការណ៍
- ការពិភាក្សាតាមទូរស័ព្ទ (ពត៌មានលំអិតនៅទំព័រទី 30)
- ការពិភាក្សាតាមអ៊ីម៉ែល (ទទួលការឆ្លើយឆ្លងគ្នាអស់២៤ម៉ោង)
+ ការតម្រូវតាមទ្រង់ទ្រាយជាអ៊ីម៉ែលពីគេហទំព័រការពិភាក្សាជាភាសាកំណើតក្នុងគេហទំព័ររបស់អង្គការ
ii. ការពិភាក្សា · សេចក្តីរាយការណ៍ក្នុង ការិយាល័យភូមិភាគ · ការិយាល័យសាខា
(មានអាស័យដ្ឋាននិងទំនាក់ទំនងនៃ ការិយាល័យភូមិភាគ · ការិយាល័យសាខានៅទំព័រទី 92)
iii. ជំនួយក្នុងការប្តូរកន្លែងហ្វឹកហ្វឺន
- ក្នុងករណីដូចខាងក្រោមនេះផ្តល់ជំនួយ
+ ក្នុងករណីពិបាកធ្វើការហ្វឹកហ្វឺនជំនាញ ពេលដែលអ្នកចង់បន្តការហ្វឹកហ្វឺនជំនាញតទៅទៀត។
- អំពីការប្តូរកន្លែងហ្វឹកហ្វឺន សុំពិភាក្សាជាមួយការពិភាក្សាជាភាសាកំណើតឬទីចាត់ការធំអង្គភាព ការិយាល័យភូមិភាគ · ការិយាល័យសាខា។ម៉្យាងទៀត សុំប្រើប្រាស់គេហទំព័រដូចខាងក្រោមនេះផងដែរ។

[គេហទំព័រជំនួយប្តូរកន្លែងហ្វឹកហ្វឺនក្នុងគេហទំព័ររបស់អង្គការ]
https://www.support.otit.go.jp/jisshu/

5. 外国人技能実習機構とは

機構は、技能実習法に基づいて設立された法務省と厚生労働省が所管する認可法人です。
機構は以下の権限・役割を果たします。



A：機構の監理団体に対する権限
①監理団体に対して実地検査を実施
定期的な実地検査／申告に基づく実地検査
②監理団体から報告を求める

B：機構の実習実施者に対する権限
①技能実習計画の認定
②実習実施者に対して実地検査を実施
定期的な実地検査／申告に基づく実地検査
③実習実施者から報告を求める
④実習実施者の届出の受理

C：機構の技能実習生に対する役割
①母国語による相談・申告への対応
○電話相談（詳細は31ページ）
○電子メールによる相談（24時間受付対応）
・機構ホームページ内母国語相談サイトからメールフォームにより対応。
②地方事務所・支所における相談・申告
（地方事務所・支所の住所連絡先は93ページ）
③実習先の変更支援
○以下のような場合に支援を行います。
・技能実習を行うことが困難になった場合で、あなたが引き続き技能実習を希望しているとき。
○実習先の変更については、母国語相談又は機構本部、地方事務所・支所に相談してください。また、以下のサイトもご活用ください。

【機構ホームページ内実習先変更支援サイト】
https://www.support.otit.go.jp/jisshu/

6. ស្តីពីភារកិច្ចនៃកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ

> កម្មសិក្សាការីហ្វឹកហ្វឺនជំនាញត្រូវភ្លេងសំស្មារតីទៅលើការហ្វឹកហ្វឺនជំនាញ ជាអាទិ៍ ហើយត្រូវខំប្រឹងប្រែងផ្ទេរជំនាញនោះទៅឱ្យប្រទេសខ្លួន។
> (ច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ មាត្រា៦)

នៅក្នុងមាត្រា៦ នៃច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ គេមានចែងអំពីភារកិច្ចរបស់កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ហើយយោងតាមភារកិច្ចនេះ គេឃើញច្បាស់លាស់ថា កម្មសិក្សាការីហ្វឹកហ្វឺនជំនាញត្រូវតែភ្លេងសំស្មារតីទៅលើការហ្វឹកហ្វឺនជំនាញ។

លោកអ្នកដែលជាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ខំប្រឹងប្រែងសិក្សាហ្វឹកហ្វឺនជំនាញនេះនៅកន្លែងហ្វឹកហ្វឺន ដោយផ្អែកលើទស្សនៈនៃច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ សូមប្រើជំនាញដែលខ្លួនបានសិក្សាហ្វឹកហ្វឺននោះជាផលប្រយោជន៍ដល់ស្រុកទេស។

ម្យ៉ាងទៀត លោកអ្នកបានមកប្រទេសជប៉ុនដោយមានលក្ខណៈសម្បត្តិ "ហ្វឹកហ្វឺនជំនាញ" ដូច្នេះមិនអាចធ្វើការងារអ្វីផ្សេងពីការហ្វឹកហ្វឺនជំនាញទេ។ ហើយក៏មិនអាចទៅធ្វើការអ្វីក្រៅពីកន្លែងដែលត្រូវទទួលការហ្វឹកហ្វឺននេះដែរ។

ហេតុនេះហើយ ទោះជានៅកន្លែងហ្វឹកហ្វឺនជំនាញក៏ដោយ ក៏មិនអាចធ្វើការងារបន្ថែមផ្សេងពីខ្លឹមសារនៃការហ្វឹកហ្វឺនជំនាញនេះដែរ។

សកម្មភាពខុសច្បាប់របស់លោកអ្នកបែបនេះ នឹងអាចត្រូវគេផ្តន្ទាទោសតាមច្បាប់ជប៉ុនកំមានដែរ។ សូមប្រយ័ត្ន។

≪បណ្តាអត់បាត់ខ្លួននៃកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ≫

ប៉ុន្មានឆ្នាំថ្មីនេះ៖ កម្មសិក្សាការីហ្វឹកហ្វឺនជំនាញដែលមកហ្វឹកហ្វឺនជំនាញនៅជប៉ុន
ហើយអត់បាត់ខ្លួនពាក់កណ្តាលទី ពីកន្លែងហ្វឹកហ្វឺន កើនឡើងយ៉ាងច្រើន ហើយដែលជាបញ្ហាធំមួយ។

ការអត់បាត់ខ្លួនពីកន្លែងហ្វឹកហ្វឺនជំនាញ ទៅធ្វើការងារផ្សេង គឺជាសកម្មភាពក្រៅពីសកម្មភាពដែលគេអនុញ្ញាតឱ្យធ្វើក្នុងលក្ខណៈសម្បត្តិស្នាក់នៅ ដែលមានចែងក្នុងច្បាប់អន្តោប្រវេសន៍ ហើយសកម្មភាពនោះនឹងអាចក្លាយទៅជាគោលដៅនៃការបណ្តេញចេញពីប្រទេសដោយបង្ខំ ព្រមទាំងជាអំពើមួយដែលអាចត្រូវគេចាត់ការក្នុងមានជាបទល្មើស គឺគ្មានប្រយោជន៍អ្វីសម្រាប់អ្នកឡើយ។ ហេតុនេះហើយ ទោះជាបានដំណឹងតាមរយៈមិត្តភក្តិ ឬ SNS ថា "បើសិនជាគេចេញពីកន្លែងហ្វឹកហ្វឺន នឹងអាចរកការងារដែលមានប្រាក់ខែថ្លៃជាង" ក៏ដោយ ក៏មិនត្រូវធ្វើតាមការញុះញង់របស់គេជាដាច់ខាត។

ការអត់បាត់ខ្លួននេះ គឺជាអំពើខុសច្បាប់ ហើយមិននាំមកនូវផលប្រយោជន៍អ្វីទាំងអស់ចំពោះលោកអ្នក។ ដូច្នេះ មិនត្រូវធ្វើតាមការញុះញង់ទាំងនេះ ហើយអត់បាត់ខ្លួនជាដាច់ខាត។

≪ទោសបញ្ញត្តិជាអាទិ៍ ក្នុងច្បាប់អន្តោប្រវេសន៍≫

ទោសស្នាក់នៅខុសច្បាប់ : ជាប់ពន្ធនាគារដោយមានការបង្ខំឱ្យធ្វើការក្រោមឬស្មើនឹង៣ឆ្នាំ ឬពិន័យជាប្រាក់ក្រោមឬស្មើនឹង៣០០ម៉ឺនយេន។

ទោសធ្វើសកម្មភាពក្រៅលក្ខណៈសម្បត្តិនៃការស្នាក់នៅ : ជាប់ពន្ធនាគារដោយមានការបង្ខំឱ្យធ្វើការ ឬជាប់ពន្ធនាគារក្រោមឬស្មើនឹង១ឆ្នាំ
ឬពិន័យជាប្រាក់ ក្រោមឬស្មើនឹង២០០ម៉ឺនយេន។

(ចំពោះករណីដែលមានការបំពានច្បាប់ជាក់ស្តែង អាចជាប់ពន្ធនាគារដោយមានការបង្ខំឱ្យធ្វើការ ឬជាប់ពន្ធនាគារស្មើនឹង៣ឆ្នាំ ឬពិន័យជាប្រាក់ ក្រោមឬស្មើនឹង៣០០ម៉ឺនយេន។)

ទោសញុះញង់ការធ្វើការងារខុសច្បាប់ : ជាប់ពន្ធនាគារដោយមានការបង្ខំឱ្យធ្វើការក្រោមឬស្មើនឹង៣ឆ្នាំ ឬពិន័យជាប្រាក់ក្រោមឬស្មើនឹង៣០០ម៉ឺនយេន។

7. ស្តីពីសោហ៊ុយដែលបង់ឱ្យស្ថាប័នបញ្ជូន ជាអាទិ៍ មុនមកជប៉ុន (ស្តីពីទំនាក់ទំនងមិនត្រឹមត្រូវរវាងអង្គភាពគ្រប់គ្រង និង ស្ថាប័នបញ្ជូន)

ស្តីពីសោហ៊ុយដែលកម្មសិក្សាការីហ្វឹកហ្វឺនជំនាញបានបង់មុនពេលមកជប៉ុន នៅក្នុងឯកសារដែលត្រូវបានដាក់មកអង្គភាពយើងខ្ញុំ មានសរសេរច្បាស់លាស់គឺ "ឯកសារលំអិតស្តីពីសោហ៊ុយដែលស្ថាប័នបញ្ជូនបរទេសបានយក (ឯកសារយោងទម្រង់លេខ 2-10)" (ខាងក្រោមនេះហៅកាត់ថា "ឯកសារលំអិតស្តីពីសោហ៊ុយ" ស្ថាប័នបញ្ជូនជាដើម មិនអាចយកសោហ៊ុយក្រៅពីសោហ៊ុយដែលមានបញ្ជាក់ក្នុងនោះពីកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ឬពីអ្នកពាក់ព័ន្ធ (ក្រុមគ្រួសារ ជាអាទិ៍) ទេ ក្រៅពីនេះ ស្ថាប័នបញ្ជូនកំបានធ្វើកិច្ចសន្យាអំពីការពន្យល់ឱ្យកម្មសិក្សាការីហ្វឹកហ្វឺនជំនាញយល់បានច្បាស់លាស់ស្តីពីសោហ៊ុយដែលត្រូវយកនេះដែរ។ បើសិនជាគេបានយកប្រាក់ធានាដើម្បីបង្ការកុំឱ្យកម្មសិក្សាការីហ្វឹកហ្វឺនជំនាញគេចាត់ខ្លួន ជាអាទិ៍ ឬកំបើសិនជាស្ថាប័នបញ្ជូន ឬអង្គភាពក្រៅពីស្ថាប័នបញ្ជូនណាមួយ ឬបុគ្គលណាម្នាក់ជាអាទិ៍ បានយកប្រាក់ក្រៅពីសោហ៊ុយដែលមានសរសេរនៅក្នុងឯកសារលំអិតស្តីពីសោហ៊ុយ សូមមកពិគ្រោះនឹងអង្គភាពយើងខ្ញុំ(សូមមើលទំព័រ 92)។

ម្យ៉ាងទៀត នៅក្នុងច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ មាត្រា២៨ កថាខ័ណ្ឌទី១ មានចែងថា អង្គភាពគ្រប់គ្រងមិនត្រូវយកសោហ៊ុយ ឬយកប្រាក់អត្ថប្រយោជន៍អ្វីមួយពាក់ព័ន្ធនឹងការគ្រប់គ្រង ពីអ្នកអនុវត្តការហ្វឹកហ្វឺនជំនាញ ឬពីកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ឬពីអ្នកពាក់ព័ន្ធដទៃទៀត នៃការហ្វឹកហ្វឺនជំនាញប្រភេទគ្រប់គ្រងដោយអង្គភាពបានឡើយជាករណីលើកលែង នៅក្នុងមាត្រាដដែល កថាខ័ណ្ឌទី២បានចែងថា ស្តីពីចំណា

６．技能実習生の責務について

> 技能実習生は、技能実習に専念することにより技能等の修得等をし、本国への技能等の移転に努めなければならない。
>
> （技能実習法第6条）

技能実習法第6条には技能実習生の責務が規定されており、この責務からも明らかなように、技能実習生は技能実習に専念することとされています。

技能実習生の皆さんは、この技能実習法の理念に基づき実習先で技能を修得し、本国で修得した技能を役立ててください。

また、技能実習生の皆さんは、在留資格「技能実習」で本邦に入国しており、技能実習以外の、他の仕事をすることはできません。実習先以外の他所で、仕事をすることもできません。

したがって、たとえ同じ実習先であっても技能実習以外の仕事として、アルバイトをすることは認められていません。

これらの行為は、あなた自身も日本の法令により処罰を受ける場合もありますので、注意してください。

≪技能実習生の失踪問題≫

近年、技能実習生として来日したにもかかわらず、技能実習の途中で実習先から失踪する者が増加しており、大きな問題となっています。

実習先から失踪して別の仕事をすることは、入管法の資格外活動許可違反として退去強制の対象となりうるほか、犯罪として処罰されることのある行為であり、みなさんにとって何ら利益になりません。ですから、友人やＳＮＳなどを通じて「実習先から失踪すれば、もっとお金が稼げる仕事がある。」などの誘いがあったとしても決してこのような誘いに乗ってはいけません。

失踪は法違反者となるだけであり、皆さんにとって何らの利益も生じませんので、絶対に失踪して他の仕事に就くことへの誘いには応じないようにしてください。

≪入管法の罰則等≫

不法残留罪：3年以下の懲役若しくは300万円以下の罰金

資格外活動の罪：1年以下の懲役若しくは禁固若しくは200万円以下の罰金
（専ら行っていると明らかに認められる場合は、3年以下の懲役若しくは禁固若しくは300万円以下の罰金）

不法就労助長罪：3年以下の懲役若しくは300万円以下の罰金

７．入国前に送出機関等に支払う費用について （監理団体と送出機関の不適切な関係について）

技能実習生の皆さんが、日本に入国する前に支払う費用については、機構あてに提出する書類の中で、「外国の送出機関が徴収する費用明細書（参考様式第２－１０号）」（以下「費用明細書」という。）において明記され、送出機関等は、当該費用以外の金銭を技能実習生及びその関係者（親族等）から徴収することはできず、また、徴収する費用の内容についても、技能実習生に十分に理解させることを送出機関が誓約することとなっています。皆さんが失踪防止などを目的として保証金を徴収されたり、送出機関あるいは送出機関以外の組織、個人等から費用明細書以外の金銭を徴収されたりした場合は、機構に相談してください(93ページ参照)。

また、技能実習法第２８条第１項には、監理団体が監理事業に関し、団体監理型実習実施者等、団体監理型技能実習生その他の関係者から、いかなる名義でも、手数料又は報酬を受けてはならないことが規定されています（ただし、その例外として、同条第２項において、監理事業

យជាអាទិ៍ដែលចាំបាច់ជាធម្មតាក្នុងគម្រោងហ្វឹកហ្វឺនជំនាញ គឺអាចយកបាន ដោយបង្ហាញច្បាស់លាស់ជាមុនអំពីការប្រើ និងទឹកប្រាក់នោះ។ នេះគេហៅថា "សោហ៊ុយគ្រប់គ្រង"។) ក្នុងករណីដែលអង្គភាពគ្រប់គ្រងបានទទួលប្រាក់ដែលមិនមែនជាសោហ៊ុយគ្រប់គ្រងពីអ្នកពាក់ព័ន្ធនឹងគម្រោងហ្វឹកហ្វឺនជំនាញ រួមទាំងស្ថាប័នបញ្ជូន (ឧទាហរណ៍ ករណីដែលអង្គភាពគ្រប់គ្រងបានទទួលប្រាក់ទឹកតែពីស្ថាប័នបញ្ជូនជាអាទិ៍) អង្គភាពគ្រប់គ្រងនោះអាចជាមុខសញ្ញានៃទោសបញ្ញត្តិលុបចោលនូវអាជ្ញាប័ណ្ណជាអង្គភាពគ្រប់គ្រង ហេតុនេះហើយ បើសិនជាលោកអ្នកបានទទួលដំណឹងបែបនេះ សូមពិគ្រោះនឹងអង្គភាពយើងខ្ញុំ។

ម្យ៉ាងទៀត កម្មសិក្សាការីហ្វឹកហ្វឺនជំនាញដែលមកពិគ្រោះអំពីបញ្ហាទាំងនេះ មិនទទួលនូវការចាត់ចែងដែលធ្វើឱ្យបាត់បង់នូវផលប្រយោជន៍អ្វីមួយឡើយ។



8. ការត្រៀមចិត្តសម្រាប់ការហ្វឹកហ្វឺនជំនាញ

(1) ១ថ្ងៃត្រូវចាប់ផ្តើមពី "គារវកិច្ច"

ពេលទៅធ្វើការ សូមធ្វើគារវកិច្ចសួរគ្នាយ៉ាងរួសរាយសិន។

តាមរយៈគារវកិច្ចនេះ គេនឹងមានអារម្មណ៍ល្អដើម្បីចាប់ផ្តើម១ថ្ងៃ ហើយកន្លែងធ្វើការដែលគារវកិច្ចសួរគ្នាទៅវិញទៅមកអាចបង្កើនឲ្យមានទំនាក់ទំនងនឹងអ្នកដទៃទៀតដោយមានភាពសុខុដុម និងមានបរិយាកាសរួសរាយល្អ។

ម្យ៉ាងទៀត ដោយមានទំនាក់ទំនងយ៉ាងសកម្មនេះអាចជួយឲ្យមានទំនាក់ទំនងល្អជាមួយនឹងអ្នកឯទៀតនៅកន្លែងធ្វើការ ហើយអាចសង្ឃឹមថាអាចទទួលលទ្ធផលធំក្នុងការហ្វឹកហ្វឺនជំនាញផងដែរ។

(2) ការគោរពវិន័យ

ក្នុងសហគ្រាសមនុស្សជាច្រើនធ្វើការ។ហេតុដែលស្រួលប្រព្រឹត្តគឺដោយសារធ្វើតាមវិន័យដែលបានកំណត់។

ដោយរក្សាពេលវេលានិងគោរពក្តីសន្យា អ្នកនឹងត្រូវបានទុកចិត្ត។ សូមយល់ឲ្យច្បាស់លាស់ហើយធ្វើសកម្មភាពតាមវិន័យដែលបានកំណត់និងតាមការណែនាំរបស់បុគ្គលិកណែនាំក្នុងការហ្វឹកហ្វឺនជំនាញបុគ្គលិកណែនាំជីវភាពរស់នៅ។

(3) សូមទទួលការណែនាំយ៉ាងយកចិត្តទុកដាក់

ប្រសិនបើគិតពីអ្វីផ្សេងទៀត ភ្លាត់ស្មារតី ធ្វើការដោយបង្ខំចិត្ត មិនអាចបណ្តុះឲ្យមានអ្វីដែលបានត្រូវណែនាំទេ បណ្តាលឲ្យមានគ្រោះថ្នាក់នៅពេលធ្វើការក៏មិនដឹងដែរ។

ជាការសំខាន់ដែលទទួលការណែនាំរបស់អ្នកពន្យល់ អោយបានហ្មត់ចត់។

(4) អ្វីក៏ដោយរហូតដល់យល់

អ្វីដែលសំខាន់បំផុតនៅពេលហ្វឹកហ្វឺនជំនាញបន្តទៅមុខគឺប្រសិនបើមានអ្វីដែលអត់យល់ អ្វីដែលអត់ស្គាល់ អ្វីដែលអត់ទាន់ចេះ អាចបណ្តាលអោយមានគ្រោះថ្នាក់ប្រសិនបើអ្នកបន្តធ្វើការដោយគ្មានការយល់ដឹង។ សូមបញ្ជាក់ដដែល។ប៉ុន្មានដងក៏ដោយដែលរហូតដល់បានយល់។

に通常必要となる経費等については、あらかじめ用途及び金額を明示した上で徴収することができるとされています。これを「監理費」といいます。)。監理団体が監理費に該当しない金銭を送出機関を含む技能実習の関係者から受け取った場合（例えば、監理団体が送出機関等からキックバックを受け取った場合）は、当該監理団体は監理団体の許可の取消しや罰則の適用対象となりますので、もし、このようなことを知った時には、機構に相談してください。

なお、これらの相談をすることによって技能実習生の皆さんが不利益に取り扱われることはありません。



８．技能実習にあたっての心構え

(1) 一日のはじまりは「あいさつ」から

出勤したら、まずは元気にあいさつをしましょう。

あいさつをすることで気持ちのいい一日を始めることができますし、あいさつが交わされる職場では、協調性のある人間関係や明るい雰囲気が生まれてきます。

また、積極的にコミュニケーションを取ることで、職場の人間関係も良好となり、技能実習においても大きな成果を上げることが期待できます。

(2) ルールを守る

企業では、多くの人たちが働いています。スムーズに行動できるのは、決められた規則を守っているからです。時間や約束を守ることで、あなたは信頼を得るでしょう。決められた規則を守り、技能実習指導員・生活指導員の指示を確実に理解して行動しましょう。

(3) 真剣に指導を受けましょう

別のことを考えていたり、ぼんやりしていたり、いやいやながら作業をしていては、指導されたことが身につきませんし、作業中に危険を招くことにもなりかねません。

説明者の指導を、真剣に受けることが大切です。

(4) 何事もわかるまで

技能実習を進めていくうえで最も重要なことは、わからない、知らない、できないまま先に進まないことです。よくわからないまま作業を続けるのは危険です。恥ずかしがらずに理解できるまで、何回でも繰り返し確認しましょう。

9. ការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្តិ ជាអាទិ៍

(1) ក្នុងកំឡុងពេលអ្នកស្នាក់អាស្រ័យនៅស្រុកជប៉ុន បានត្រូវអនុលោមតាមច្បាប់ស្រុកជប៉ុននានាដូចតទៅនេះ។

ឈ្មោះច្បាប់	ចំណុច
ច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ	- ដើម្បីការពារកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ មានទង្វើត្រូវហាមឃាត់ដល់អ្នកពាក់ព័ន្ធហ្វឹកហ្វឺនជំនាញ។ ក្នុងករណីល្មើសច្បាប់ កម្មសិក្សាការីហ្វឹកហ្វឺនជំនាញអាចរាយការណ៍ទៅប្រធានមន្ទីរគ្រប់គ្រងអន្តោប្រវេសន៍ស្នាក់នៅនិងរដ្ឋមន្ត្រីសុខាភិបាល ការងារនិងសុខុមាលភាពបាន។ - អង្គភាពកំណត់ការធ្វើការតម្រូវតាមជំនួយការការពារចំពោះការពិភាក្សារបស់កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ។
ការគ្រប់គ្រងចេញចូលប្រទេសឬច្បាប់ទទួលស្គាល់ជនភៀសខ្លួន (ច្បាប់អន្តោប្រវេសន៍និងទទួលស្គាល់ជនភៀសខ្លួន)	- កំណត់ភាពមានសិទ្ធិ (ភាពមានសិទ្ធិស្នាក់នៅ)ដើម្បីជនបរទេសស្នាក់នៅ(ស្នាក់អាស្រ័យ) ស្រុកជប៉ុនតាមរបៀបដែលច្បាប់តម្រូវ ហើយកំណត់សកម្មភាពដែលអាចធ្វើនៅស្រុកជប៉ុន។ - ដោយសារអ្នកមានភាពមានសិទ្ធិដែលបានត្រូវអនុញ្ញាតការហ្វឹកហ្វឺនជំនាញ ដូច្នេះសកម្មភាពដែលមិនបានទទួលការយល់ព្រម មិនអាចធ្វើបានទេ ដូចជាធ្វើការនៅផ្ទះនិងធ្វើការក្រៅ។
ច្បាប់ស្តង់ដាការងារ ច្បាប់ប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីអនាម័យ និងសុវត្ថិភាពការងារ	- អ្នកទាំងអស់គ្នាដែលជាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញនឹងធ្វើការជាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញក្រោមទំនាក់ទំនងការងារជាមួយអ្នកអនុវត្តការហ្វឹកហ្វឺន ដូច្នេះត្រូវអនុលោមតាមច្បាប់ស្តង់ដាការងារជាដើមដូចកម្មករឯទៀតដែលធ្វើការនៅស្រុកជប៉ុនដែរ។(ដែលក្នុងករណីចូលហ្វឹកហ្វឺនជំនាញក្រោយចូលប្រទេសមួយរំពេច នឹងត្រូវអនុលោមក្រោយនឹងបញ្ចប់ការហ្វឹកហ្វឺនជំនាញ។) - ច្បាប់ទាំងនេះបានកំណត់ខ្នាតទាបបំផុតនៃលក្ខខណ្ឌការងារក្នុងករណីមានការល្មើសច្បាប់អាចរាយការណ៍ចំពោះការយោល័យត្រួតពិនិត្យការងារបាន។
ច្បាប់ស្តីពីឱកាសការងារស្មើភាពគ្នារវាងបុរសនិងស្ត្រី	- កម្មសិក្សាការីហ្វឹកហ្វឺនជំនាញទាំងអស់ ដោយបំពេញការងារក្នុងនាមជាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញក្នុងកិច្ចសន្យាការងារជាមួយអ្នកអនុវត្តកម្មសិក្សា ដូច្នេះមិនត្រូវបានទទួលស្គាល់ថាការចាត់ការលក្ខណៈបាត់បង់ប្រយោជន៍ដូចជាការបណ្តេញចេញពីការងារដោយមូលហេតុដូចជារៀបអាពាហ៍ពិពាហ៍មានផ្ទៃពោះសម្រាលកូនជាដើម តាមច្បាប់ស្តីពីឱកាសការងារស្មើភាពគ្នារវាងបុរសនិងស្ត្រី។ - ក្នុងករណីទទួលការចាត់ការដូចខាងលើ សូមមកពិគ្រោះយោបល់នៅមន្ទីរការងារខេត្តក្រុង។
ច្បាប់សហជីព ច្បាប់ស្តីពីការសម្របសម្រួលការងារ	- កម្មសិក្សាការីហ្វឹកហ្វឺនជំនាញមានសិទ្ធិចូលជាសមាជិកសហជីព ហើយចចាជាសមូហភាពនឹងនិយោជក ដើម្បីទាមទារនូវការលើកកំពស់លក្ខខ័ណ្ឌការងារជាអាទិ៍។ - អ្នកអនុវត្តការហ្វឹកហ្វឺន(អាចមានករណីអង្គភាពគ្រប់គ្រងដែរ) មិនអាចចាត់ចែងអ្វីមួយចំពោះកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ដែលធ្វើឱ្យខូចប្រយោជន៍អ្នកនោះ: ដូចជាការដេញចោលដោយយកមូលហេតុថា អ្នកនោះបានចូលជាសមាជិកសហជីព ឬបានធ្វើសកម្មភាពក្នុងសហជីព ហើយមិនអាចទាមទារឱ្យអ្នកនោះចេញពីសហជីព ជាដើមបានឡើយ។ - ក្នុងករណីដែលបានទទួលនូវការចាត់ចែងបែបនេះ: កម្មសិក្សាការីនោះអាចទាមទារឱ្យគណកម្មការពលកម្មជួយសង្គ្រោះខ្លួនបាន។
ច្បាប់ឯទៀត	- អនុលោមតាមច្បាប់ដែលទាក់ទងនឹងការធានារ៉ាប់រងក្នុងសង្គម(ការធានារ៉ាប់រងសុខភាពនិងប្រាក់ខែនិវត្តន៍) ការធានារ៉ាប់រងការងារ ពន្ធជាដើម។

ត្រូវបានការពារសិទ្ធិរបស់អ្នកដោយច្បាប់ទាំងនេះដូចកម្មកររដែលជាជនជាតិជប៉ុន តែ សូមកុំភ្លេចថាមានកាតព្វកិច្ចដែលត្រូវតែធ្វើតាមដូចគេ។

(2) ដើម្បីកុំឱ្យពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម

ពេលថ្មីៗនេះ មានក្រុមឧក្រិដ្ឋករជាច្រើន បានផ្សាយព័ត៌មានស្តីពីការរកបុគ្គលិកធ្វើការ តាមរយៈអ៊ីនធឺណិតឬតាមរយៈ: SNS ចំពោះជនបរទេស ឬតាមរយៈមិត្តភក្តិ អ្នកស្គាល់គ្នា ជាដើម ហើយគេឃើញថា មានកម្មសិក្សាការីហ្វឹកហ្វឺនជំនាញខ្លះបានចូលអន្ទាក់ឧក្រិដ្ឋកម្មរបស់គេ។

9. 法令の適用等

（１）あなたが日本に滞在する間に、次のような日本の各種法令が適用されます。

法令の名前	ポイント
技能実習法	○技能実習生を保護するため、技能実習関係者による禁止行為を定めています。法令違反があった場合には、技能実習生は出入国在留管理庁長官及び厚生労働大臣に申告することができます。 ○機構が技能実習生の相談への対応・援助・保護を行うことを定めています。
出入国管理及び難民認定法 （入管法）	○外国人が日本で適法に在留（滞在）するための資格（在留資格）を規定しており、日本で行うことができる活動を定めています。 ○あなたが許可されている資格は「技能実習」になりますので、この資格で認められない活動、たとえば、内職やアルバイトをすることはできません。
労働基準法 最低賃金法 労働安全衛生法	○技能実習生の皆さんは、実習実施者との雇用関係のもと技能実習生として働くことになりますので、日本で働く他の労働者と同じように、労働基準法などが適用されます。（なお、入国直後に講習を受ける場合は、講習終了後から適用されます。） ○これらの法律は労働条件の最低の基準を定めています。法令違反があった場合には、労働基準監督署に申告することができます。
男女雇用機会均等法	○技能実習生の皆さんは、実習実施者との雇用関係のもと技能実習生として働くことになりますので、日本で働く他の労働者と同じように、使用者が結婚・妊娠・出産等を理由として解雇など不利益取扱いをすることは男女雇用機会均等法で認められていません。 ○これらの取扱いを受けた場合は、都道府県労働局へ相談してください。
労働組合法 労働関係調整法	○技能実習生は、労働組合に加入し、労働条件の向上などを求めて使用者に対して団体交渉をする権利があります。 ○実習実施者（場合によっては監理団体も）が、技能実習生に対し、組合加入や組合活動を理由に解雇をしたり、組合脱退を求めるなどの不利益な取扱いをすることはできません。 ○これらの取扱いを受けた場合には、労働委員会に救済を求めることができます。
その他の法律	○社会保険（健康保険や年金）、労働保険、税金に関する法律なども適用になります。

これらの法令によって、日本人労働者と同じように、あなたの権利は保護されることになりますが、同じように、果たさなくてはならない義務があることも忘れないようにしてください。

（２）犯罪に巻き込まれないために

近年、犯罪組織が、外国人向けのインターネットの情報やSNSの求人広告、友人や知人からの勧誘等を使って、さまざまな犯罪に技能実習生を巻き込んでいる例が見られます。

មុនពេលវិលត្រឡប់ទៅស្រុកវិញធ្វើការអនុប្បទាន ឬលក់គណនីធនាគារ សៀវភៅធនាគារ កាតធនាគារ ទូរស័ព្ទដៃ ដែលខ្លួនបានប្រើពីមុនមក ទៅឱ្យអ្នកដទៃ។



ឱ្យកម្មសិក្សាការីទៅដកប្រាក់ពីគណនីធនាគាររបស់អ្នកដទៃ តាមរយៈម៉ាស៊ីន ATM។

ក្លែងបន្លំជាអ្នកដទៃ ចុះឈ្មោះនិងហត្ថលេខាលើប័ណ្ណធ្វើទំនិញទៅអ្នកដទៃ ឬបន្លំយករបស់ដែលគេធ្វើមកឱ្យអ្នកដទៃ។

គេគិតឃើញខ្លីៗទៅថា ការងារទាំងនេះជាការងារងាយស្រួល ហើយបានប្រាក់ច្រើនល្អាម។ តែអំពើទាំងនេះ សុទ្ធតែជាឧក្រិដ្ឋកម្ម។ ក្រុមឧក្រិដ្ឋករបានទិយាយផ្អែមល្ហែម បញ្ចុះបញ្ចូលកម្មសិក្សាការីហ្វឹកហ្វឺនជំនាញថា "សាកល្បងធ្វើការងារតាមម៉ោងបន្តិចមើល" ជាដើម ហេតុនេះហើយមានករណីខ្លះដែលកម្មសិក្សាការីហ្វឹកហ្វឺនជំនាញដែលទទួលរង ប្រព្រឹត្តអំពើទាំងនេះដោយមិនដឹងខ្លួនថាអំពើនេះជាឧក្រិដ្ឋកម្មផង។

ទោះជាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញត្រូវក្រុមឧក្រិដ្ឋកប្រើបែបនេះក៏ដោយ កំអ្នកទាំងអស់គ្នានឹងត្រូវគេចោទប្រកាន់ដោយសារបានចូលដៃដល់អំពើឧក្រិដ្ឋចំពោះអំពើណាដែលមាននៅក្នុងតារាងខាងក្រោម ហើយការពិតអ្នកទាំងអស់គ្នានឹងហ្វឹកហ្វឺនជំនាញនិងវិលត្រឡប់ទៅដល់ស្រុកវិញនិងជួបជុំក្រុមគ្រួសារដោយសុវត្ថិភាព តែមិនបានសម្រេចគោលបំណងនោះ ដោយត្រូវជាគោលដៅនៃទោសប្រហារ៉ណ្ឌឬការបញ្ជូនត្រឡប់ទៅស្រុកដោយបង្ខំ ជាអាទិ៍ ដូច្នេះ សូមប្រយ័ត្នកុំឱ្យជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មបែបនេះ។

បើសិនជាលោកអ្នកបានឃើញ ឬបានឮអំពីឧក្រិដ្ឋកម្មបែបនេះ សូមជូនដំណឹងទៅនគរបាល។ ម្យ៉ាងទៀតក្នុងករណីលែងប្រើប្រាស់គណនីធនាគារដោយសារការវិលត្រឡប់ទៅស្រុកវិញជាដើម សូមចាត់ការរំលាយកិច្ចសន្យាប្រើគណនី។

帰国前にこれまで使っていた自分名義の預金通帳・キャッシュカード・携帯電話を他者に譲渡したり売ったりすること。



ＡＴＭで他人名義の口座から現金を引き出すこと。

他人になりすまして配達伝票に署名したり、他人の宅配便をだまし取ったりすること。

こうした仕事は、表向きは簡単で、すぐに高額報酬を得られ、好条件の仕事のように見えますが、すべて犯罪行為です。犯罪組織は、「ちょっとアルバイトをしてみないか。」などと、技能実習生の皆さんを言葉巧みに勧誘しますので、巻き込まれた技能実習生においては、自らの行為が犯罪行為であるとの自覚がないまま行っている場合もあります。

技能実習生の皆さんがこのようなかたちで犯罪組織に利用された場合であっても、例えば、下の表にあるような行為については、犯罪行為に加担したとして、罪に問われる可能性があり、本来、技能を身につけて、家族の元に無事帰国するはずが、その目的を果たすことができずに、刑事罰や強制送還等の対象となりますので、このような犯罪に巻き込まれないように注意してください。

もし、こうした行為を見聞きしたら、警察に通報してください。なお、帰国などにより銀行口座を利用しなくなる場合は、解約手続をしてください。

អំពើដែលត្រូវនឹងនក្រិដ្ឋកម្ម	ឈ្មោះព្រហ្មទណ្ឌត្រូវនឹងអំពើខាងឆ្វេង
ការអនុប្បទានទូរស័ព្ទដៃទៅឱ្យអ្នកដទៃ	ផ្គួបនឹងច្បាប់ស្តីពីការប្រើមិនត្រឹមត្រូវនូវទូរស័ព្ទដៃ
ការលក់ ឬអនុប្បទានគណនីធនាគារ ឬកាតធនាគារទៅឱ្យអ្នកដទៃ	ច្បាប់ការពារនូវការផ្ទេរផលប្រយោជន៍បានមកពីឧក្រិដ្ឋកម្ម
ការទទួលដោយអនុប្បទាននូវកាតធនាគាររបស់អ្នកដទៃ ក្នុងគោលបំណងដកប្រាក់ពីធនាគារដោយស្លៀងបន្លំប្រើឈ្មោះអ្នកដទៃ	ច្បាប់ការពារនូវការផ្ទេរផលប្រយោជន៍បានមកពីឧក្រិដ្ឋកម្ម
ការចុះហត្ថលេខា ឬបោះត្រាលើប័ណ្ណផ្ញើទំនិញ ដោយស្លៀងបន្លំយកឈ្មោះអ្នកដទៃ	ការស្លៀងបន្លំត្រាឬហត្ថលេខារបស់អ្នកដទៃ
ការឆបោកយកទំនិញដែលគេផ្ញើឱ្យអ្នកដទៃ	ការឆបោក
ការដកប្រាក់ពីគណនាធនាគាររបស់អ្នកដទៃតាមរយៈ ATM	ចោរកម្ម

10. ប័ណ្ណស្នាក់នៅ

ប័ណ្ណស្នាក់នៅ គឺជាប័ណ្ណដែលគេប្រគល់ជូនចំពោះជនបរទេសដែលមកស្នាក់នៅជប៉ុនរយៈពេលមធ្យម ឬវែង ពេលដែលគេអនុញ្ញាតដូចជាពេលចូលប្រទេសជប៉ុន ឬពេលអនុញ្ញាតឱ្យប្តូរលក្ខណៈសម្បត្តិនៃការស្នាក់នៅ ឬពេលអនុញ្ញាតឱ្យពន្យារកំឡុងពេលស្នាក់នៅ ជាដើម។

អ្នកមានកាតព្វកិច្ចដែលកាន់ជាប់ជានិច្ចនូវប័ណ្ណស្នាក់នៅ ដូច្នេះសូមជាប់ខ្លួនជាកុំខាន។

សូមកុំផ្ទេរប័ណ្ណស្នាក់នៅទៅអង្គភាពគ្រប់គ្រងនិងអ្នកអនុវត្តការហ្វឹកហ្វឺន។

ម៉្យាងទៀត សូមកុំឲ្យអ្នកឯទៀតខ្ចីឬឲ្យប័ណ្ណស្នាក់នៅ។សូមប្រុងប្រយ័ត្នព្រោះក្រែងលោគេប្រើប្រាស់តាមរបៀបល្មើសនិងធ្វើឲ្យជាប់ទាក់ទងនឹងបទឧក្រិដ្ឋកម្ម។

ទីលំនៅ
ករណីបានផ្លាស់ប្តូរ
មានចុះនៅខាងក្រោយ។

ការមាននិងគ្មានកម្រិតការងារ
មិនអាចធ្វើសកម្មភាពការងារ
ក្រៅពីការហ្វឹកហ្វឺនជំនាញ។

កំឡុងពេលស្នាក់នៅ
(ថ្ងៃផុតកំណត់)
បញ្ជាក់នូវកំឡុងពេលដែល
អាចស្នាក់នៅស្របច្បាប់។

កំឡុងពេលសុពលភាព
នៅលើប័ណ្ណស្នាក់នៅ
មានបញ្ជាក់អំពីកំឡុងពេលសុពលភាព។

កូឡុនបញ្ជាក់អំពីសកម្មភាពដែលអាចធ្វើបានក្រៅពីលក្ខណៈសម្បត្តិដែលបានទទួលកម្មសិក្សាការហ្វឹកហ្វឺនជំនាញមិនអាចទទួលនូវការអនុញ្ញាតឱ្យធ្វើសកម្មភាពក្រៅលក្ខណៈសម្បត្តិនៃការស្នាក់នៅបានឡើយ។

犯罪に該当する行為	左記の行為が該当する罪名
他人に携帯電話を譲り渡すこと	携帯電話不正利用防止法違反
他人に銀行口座やキャッシュカードを売る、譲ること	犯罪収益移転防止法違反
他人になりすまして現金を引き出す目的で、他人名義のキャッシュカードを譲り受けること	犯罪収益移転防止法違反
他人になりすまして配達伝票に署名すること	私印偽造
他人の宅配便（商品）をだまし取ること	詐欺
ＡＴＭで他人名義の口座から現金を引き出すこと	窃盗

10. 在留カード

在留カードは日本に中長期に在留（滞在）する外国人に対し、上陸許可や在留資格の変更許可、在留期間の更新許可などの在留許可に伴い交付されるものです。

あなたには在留カードを携帯する義務がありますので、必ず自分で所持してください。在留カードを監理団体や実習実施者に預けないでください。

また、在留カードを他人に貸したり、譲り渡したりもしないでください。悪用されたり、犯罪に巻き込まれたりするおそれもありますので注意してください。

住居地
変更があった場合には、裏面に記載されます。

就労制限の有無
技能実習以外の就労活動はできません。

在留期間(満了日)
日本に在留することができる期間を表しています。

有効期間
在留カードには有効期間があります。

資格外活動許可欄
技能実習生は、資格外活動許可を受けることはできません。

11. ក្នុងករណីដែលមានការលំបាកក្នុងការហ្វឹកហ្វឺនជំនាញ

តាមធម្មតា ការហ្វឹកហ្វឺនជំនាញត្រូវតែអនុវត្តតាមផែនការនៃការហ្វឹកហ្វឺនជំនាញដែលត្រូវបានបង្កើតឡើងសម្រាប់កម្មសិក្សាការីហ្វឹកហ្វឺនជំនាញម្នាក់ៗ ដោយមិនអាចឈប់ពាក់កណ្តាលទីបានទេ ត្រូវតែអនុវត្តបន្ត។ (កម្មសិក្សាហ្វឹកហ្វឺនជំនាញមានជំងឺរបួស(រួមទាំងគ្រោះថ្នាក់ពលធ្វើការ។),ហេតុផលរបស់ក្រុមគ្រួសារឬសាមីខ្លួនមានផ្នែរពោះសម្រាលកូនជាដើម ហេតុផលទាំងនេះហើយដែលធ្វើអោយកម្មសិក្សាការីហ្វឹកហ្វឺនជំនាញពិបាកក្នុងការបន្តហ្វឹកហ្វឺនជំនាញ ទោះក្នុងករណីបានត្រលប់ទៅប្រទេសកំដោយ,ប្រសិនបើកម្មសិក្សាការីហ្វឹកហ្វឺនជំនាញមានបំណងនោះ គាត់អាចចាប់ផ្តើមកម្មសិក្សាហ្វឹកហ្វឺនជំនាញឡើងវិញបាន។)។

កំប៉ុន្តែ កន្លងមកនេះ គេឃើញមានករណីខ្លះៗដែលកម្មសិក្សាការីហ្វឹកហ្វឺនជំនាញត្រូវបានបញ្ជូនឱ្យត្រឡប់ទៅស្រុកខ្លួនវិញ មុនការបញ្ចប់ផែនការហ្វឹកហ្វឺនជំនាញ ដែលផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន។

ដូច្នេះហើយ នៅក្នុងច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ (របបថ្មី) ក្នុងករណីដែលមានការលំបាកនឹងបន្តការហ្វឹកហ្វឺនជំនាញ ដោយសារមានសភាពការណ៍ ដូចជាមានបញ្ហាគ្រប់គ្រងនៃកន្លែងហ្វឹកហ្វឺន ឬបញ្ហាជម្ងឺ ឬរបួសនៃកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ (រួមទាំងរបួសក្នុងការងារជាដើម) គេមានមារឱ្យអង្គភាពគ្រប់គ្រងជាអាទិ៍ ធ្វើសេចក្តីរាយការណ៍ស្តីពីការពិបាកក្នុងការអនុវត្តការហ្វឹកហ្វឺនជំនាញ ជូនអង្គភាពយើងខ្ញុំ។

ដូច្នេះហើយ នៅក្នុងច្បាប់ស្តីពីការហ្វឹកហ្វឺនជំនាញ ក្នុងករណីដែលមានការលំបាកនឹងបន្តការហ្វឹកហ្វឺនជំនាញ ដោយសារមានសភាពការណ៍ដូចជាមានបញ្ហាគ្រប់គ្រងនៃកន្លែងហ្វឹកហ្វឺន ឬបញ្ហាជម្ងឺ ឬរបួសនៃកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ (រួមទាំងរបួសក្នុងការងារ ជាដើម) គេមានមារឱ្យអង្គភាពគ្រប់គ្រងជាអាទិ៍ ធ្វើសេចក្តីរាយការណ៍ស្តីពីការពិបាកក្នុងការអនុវត្តការហ្វឹកហ្វឺនជំនាញ ជូនអង្គភាពយើងខ្ញុំ។

ម្យ៉ាងទៀត ក្នុងករណីដែលមានការពិបាកក្នុងការហ្វឹកហ្វឺនជំនាញដោយសារមូលហេតុដែលមិនអាចទៀសវាងបាន ហើយលោកអ្នកមានចិត្តចង់បន្តការហ្វឹកហ្វឺនជំនាញ អង្គភាពគ្រប់គ្រងមានភាពរឭកិច្ចរកកន្លែងហ្វឹកហ្វឺនជំនាញថ្មីទៀត។ ប៉ុន្តែបើសិនជាអង្គភាពគ្រប់គ្រងមិនបំពេញភាពរឭកិច្ចនេះទេ អង្គភាពយើងខ្ញុំនឹងជួយក្នុងការប្តូរកន្លែងហ្វឹកហ្វឺនជំនាញជូន ដូច្នេះ សូមពិគ្រោះនិងយើងខ្ញុំ ឬតាមកន្លែងពិគ្រោះជាភាសាកំណើត។

ម្យ៉ាងទៀត បើសិនជាលោកអ្នក (កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ) ត្រូវបានជម្រុញឱ្យត្រឡប់ទៅប្រទេសខ្លួនវិញផ្ទុយពីឆន្ទៈលោកអ្នកៗអាចពិគ្រោះ ឬតាមការណ៍ជូនអង្គភាព ហើយជាទីបញ្ចប់ នៅពេលបំពេញបែបបទចេញពីប្រទេសជប៉ុននៅអាកាសយានដ្ឋាន ឬកំពង់ផែលោកអ្នក អាចប្រាប់អំពីបញ្ហានេះជូនមន្ត្រីអន្តោប្រវេសន៍នៅទីនោះបាន។ លើសពីនេះក្នុងករណីដែលបានកំណត់ អ្នកអាចទទួលបានការផ្តល់នូវកន្លែងស្នាក់នៅ បណ្តោះអាសន្នពីអង្គការ។

ជំនួយផ្លាស់ប្តូរកន្លែង ការសិក្សា (គេហទំព័រជំនួយ ផ្លាស់ប្តូរកន្លែងការសិក្សា)	[គេហទំព័រជំនួយផ្លាស់ប្តូរកន្លែងការសិក្សាអង្គភាព] https://www.support.otit.go.jp/jisshu/ * ទទួលការពិភាក្សានៅការពិភាក្សាសាកំណើតនិងច្រកទំនាក់ទំនងអង្គភាព ដែរ។ * ករណីអាចទទួលជំនួយការផ្លាស់ប្តូរកន្លែងការសិក្សា - ក្នុងករណីពិបាកធ្វើការសិក្សាបច្ចេកទេសជំនាញដោយមានស្ថានភាពដែលគ្មាន ផ្លូវផងករណីចង់បន្តសិក្សាបច្ចេកទេសជំនាញដោយផ្លាស់ប្តូរកន្លែងការសិក្សាផង	ក្នុងករណីមិនអាចទទួលសហការទោះជាសុំជំនួយការផ្លាស់ប្តូរកន្លែងការសិក្សាពីក្រុមត្រួតពិនិត្យ សូមពិភាក្សាអង្គភាព។
កន្លែងស្នាក់នៅ នៅអង្គការ (ការផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ន)	ក្នុងករណីមិនអាចស្នាក់នៅក្នុងអន្តរាសិកដ្ឋានបានដោយសារមូលហេតុរងនូវអំពើមិនសមរម្យដូចជាការបៀតបៀនអំណាច,ការបៀតបៀនផ្លូវភេទនិងអំពើហឹង្សាជាដើមពីអ្នកអនុវត្តការសិក្សាឬអង្គការត្រួតពិនិត្យ	ក្នុងករណីមិនអាចទទួលបាននូវកិច្ចសហប្រតិបត្តិការពីអ្នកអនុវត្តការសិក្សាឬអង្គការត្រួតពិនិត្យ ទោះបីអ្នកបានស្នើសុំឲ្យជួយកំដោយ សូមពិគ្រោះជាមួយអង្គការ ។

12. ក្នុងករណីរៀបអាពាហ៍ពិពាហ៍មានផ្នែរពោះសម្រាលកូននៅក្នុងកំឡុងពេលបំពេញហ្វឹកហ្វឺនជំនាញ

ការដាក់កម្រិតសេរីភាពក្នុងជីវភាពឯកជនរបស់កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ច្បាប់ហាមឃាត់មិនអោយបញ្ឈប់ការងារកម្មសិក្សាការីហ្វឹកហ្វឺនជំនាញដោយយកហេតុផលការរៀបអាពាហ៍ពិពាហ៍មានផ្នែរពោះ និងសម្រាលកូនជាដើម។ម្យ៉ាងទៀត ក្នុងករណីមានផ្នែរពោះសម្រាលកូន វាជាគោលដៅនៃការឈប់សម្រាកលំហែមាតុភាពមុននិងក្រោយសម្រាលកូនដែលផ្អែកលើច្បាប់។ ក្នុងករណីធ្លាប់បានទទួលការចាត់ចែងបាត់បង់ប្រយោជន៍ឬមានករណីមិនច្បាស់លាស់ សូមមកពិគ្រោះយោបល់នៅមន្ទីរការងារខេត្តក្រុង។ អាចសុំពិគ្រោះឬដាក់ពាក្យដល់អង្គភាពបានដែរ (សូមមើលទំព័រ 30, 34)។

11. 技能実習を行うことが困難になった場合

本来、技能実習は、技能実習生ごとに作成された技能実習計画に従い、途中で中止されることなく実施されなければなりません（技能実習生の病気・怪我（労災含む。）、技能実習生の家族の都合や自身の妊娠・出産等により技能実習の実施が困難となり帰国した場合であって、技能実習生が希望する場合には、改めて技能実習を再開することができます。）。

しかし、これまで技能実習生の意に反し、技能実習計画満了前に帰国させられるという事案が一部で発生していました。

そのため、技能実習法においては、実習先の経営上の都合、技能実習生の病気や怪我（業務上の怪我などを含む。）の事情等で技能実習を継続することが困難となった場合には、監理団体等は技能実習実施困難時届出を機構に提出することが求められています。

その際に、技能実習生が技能実習計画の満了前に途中で帰国することとなる場合には、技能実習生に対し、意に反して技能実習を中止して帰国する必要がないことの説明や帰国の意思確認を書面により十分に行った上、技能実習生の帰国が決定した時点で帰国前に機構に届け出なければならないとされています。

また、やむを得ない事情で技能実習を行うことが困難となった場合で、あなたが引き続き技能実習を希望しているときには、監理団体には新たな実習実施先に転属させる責務がありますが、監理団体が責務を履行しないときは、機構において実習先変更の支援を行いますので、機構又は母国語相談に相談してください。

なお、あなた（技能実習生）の意思に反して帰国を促された場合にあっては、機構に相談や申告の申出を行うことができるほか、最終的には空海港での出国手続の際に入国審査官にその旨を申し出ることができます。このほか、一定の場合に、機構から一時宿泊施設の提供を受けることができます。

実習先の変更支援 （実習先変更支援サイト）	【実習先変更支援サイト】 https://www.support.otit.go.jp/jisshu/ ※母国語相談や機構窓口でも相談を受け付けます。 ※実習先変更支援を受けることができる場合 ・やむを得ない事情で技能実習を行うことが困難になった場合で、実習先を変更して技能実習を続けることを希望している場合	監理団体に実習先の変更支援を求めても協力が得られない場合は機構に相談してください。
機構における宿泊施設 （一時宿泊先の提供）	実習実施者や監理団体からパワハラ・セクハラ・暴力等の不適切な行為を受けたことが原因で、宿舎に宿泊することができない場合	実習実施者や監理団体に支援を求めても協力が得られない場合は、機構に相談してください。

12. 技能実習中に結婚・妊娠・出産などをした場合

技能実習生の私生活の自由を不当に制限することや結婚・妊娠・出産などを理由として、解雇など不利益な取扱いをすることは法律で禁止されています。また、妊娠・出産した場合は、法律に基づく産前産後の休業などの対象となります。不利益な取扱いを受けた場合や不明なことがある場合は、都道府県労働局へ相談してください。機構に相談や申告の申し出もできます（31ページ及び35ページ参照）。

សិទ្ធសំខាន់ៗដែលត្រូវគេទទួលស្គាល់នៅពេលមានផ្ទៃពោះ・សម្រាលកូន

- ដាក់កម្រិតស្តីពីការងារក្រៅម៉ោង, ការងារចំថ្ងៃឈប់សម្រាក, ការងារកណ្តាលយប់
  ស្ត្រីដែលកំពុងមានផ្ទៃពោះនិងក្រោយពេលសម្រាលកូនហើយ ក្នុងអំឡុងពេល១ឆ្នាំអាចស្នើរសុំ ក្នុងការលើកលែងការងារក្រៅម៉ោង,ការងារចំថ្ងៃឈប់សម្រាក,ការងារនៅកណ្តាលយប់បាន។ទោះបីក្នុងករណីអនុវត្តប្រព័ន្ធម៉ោងការងារកែប្រែក៏ដោយ អ្នកអាចស្នើសុំមិនធ្វើការលើសពីម៉ោងធ្វើការស្របច្បាប់នៃមួយថ្ងៃនិងមួយសប្តាហ៍។
- ការផ្លាស់ប្តូរការងារស្រាលៗ
  ក្នុងអំឡុងពេលមានផ្ទៃពោះ អាចស្នើសុំការផ្លាស់ប្តូរការងារណាស្រាលៗផ្សេងបាន។
- ការឈប់សំរាកលំហែមាតុភាពមុនសម្រាលកូន
  ចាប់ពី៦សប្តាហ៍មុននៃកាលបរិច្ឆេទសម្រាលកូន (ក្នុងករណីកូនភ្លោះឬលើសពីនេះ គឺចាប់ពី១៤សប្តាហ៍មុន)
  អាចទទួលបានតាមការដាក់ពាក្យស្នើសុំ។ ថ្ងៃសម្រាលកូនគឺត្រូវរាប់នៅក្នុងការឈប់សំរាកលំហែមាតុភាពមុនសម្រាលកូន
- ការឈប់សំរាកលំហែមាតុភាពក្រោយសម្រាលកូន
  ចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃសម្រាលកូនហើយ ក្នុងអំឡុងពេល៨សប្តាហ៍គឺមិនអាចបំពេញការងារបានឡើយ។ ក៏ប៉ុន្តែក្រោយពីសម្រាលកូនបាន៦សប្តាហ៍ហើយ ប្រសិនបើសាម៉ីខ្លួនបានដាក់ពាក្យស្នើរ(ចូលធ្វើការ)ហើយគ្រូពេទ្យទទួលស្គាល់ថាពុំមានផលប៉ះពាល់ដល់ការងារទេនោះ អាចទៅបំពេញការងារបានដូចដើម។
- ការដាក់កម្រិតបញ្ឈប់ការងារ
  ក្នុងអំឡុងពេល មុននិងក្រោយពេលសម្រាលកូនហើយ និងក្នុងរយៈពេល៣០ថ្ងៃក្រោយនោះ គឺត្រូវគេហាមមិនអោយបញ្ឈប់ការងារអ្នកទេ។
- ម៉ោងថែទាំកូន
  ចំពោះស្ត្រីដែលថែទាំកូនដែលកើតមិនទាន់គ្រប់អាយុ១ឆ្នាំ អាចស្នើសុំម៉ោងមើលថែទាំកូនក្នុង១ថ្ងៃបាន២ដង ម្តងៗយ៉ាងហោចណាស់បានរយៈពេល៣០នាទី។
- ការគ្រប់គ្រងសុខភាពមាតា
  ចំពោះស្ត្រីមានផ្ទៃពោះអ្នកអាចស្នើពេលវេលាសម្រាកដើម្បីទៅពិនិត្យសុខភាពមាតាបាន។
  ក្នុងករណីពិនិត្យសុខភាពហើយបានទទួលការណែនាំពីវេជ្ជបណ្ឌិតនោះ អ្នកអាចស្នើរសុំវិធានការចាំបាច់ដើម្បីធានាថាអ្នកអាចធ្វើតាមការណែនាំរបស់វេជ្ជបណ្ឌិតបាន។
  ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីសម្រាលកូនស្ត្រីអាចស្នើសុំឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិនិត្យសុខភាពនៅពេលណែនាំដោយវេជ្ជបណ្ឌិត។

នៅពេលអ្នកសំរាលកូននៅមន្ទីរពេទ្យ អ្នកនឹងទទួលបានចំនួនទឹកប្រាក់ជាក់លាក់ពីការធានារ៉ាប់រងសុខភាពរបស់អ្នក។លើសពីនេះទៀត អ្នកប្រហែលជាអាចទទួលការពិនិត្យសុខភាពដោយឥតគិតថ្លៃមុនពេលសំរាលកូន។ ជាបឋមសូមពិគ្រោះជាមួយអង្គការឬពិគ្រោះយោបល់ជាភាសាកំណើតរបស់អ្នក។

13. ការពិគ្រោះក្នុងអង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស [ការពិភាក្សាជា ភាសាកំណើត]

ក្នុងអង្គភាពការសិក្សាបច្ចេកទេសជំនាញជនបរទេស អាចទទួលការពិភាក្សាជាភាសាកំណើត(យោងតាមឧទាហរណ៍ការពិភាក្សា) ពីអ្នកទាំងអស់គ្នាដែលជាកម្មសិក្សាការីបច្ចេកទេសជំនាញដូចតទៅនេះ សូមអញ្ជើញប្រើ។

- អង្គការយើងខ្ញុំមានជំនួយនៅពេលមានការចាំបាច់ប្តូរកន្លែងហ្វឹកហ្វឺន ដោយសារមានបញ្ហាដែលមិនអាចចៀសវាងបាន ដូចជាបញ្ហាដែលកើតមានឡើងក្នុងការគ្រប់គ្រងនៃកន្លែងហ្វឹកហ្វឺនជាដើម។
- សូមទាក់ទងក្នុងករណីចង់ទទួលជំនួយករណីដូចជាក្រុមត្រួតពិនិត្យជាដើមបដិសេធការផ្តល់ទីស្នាក់នៅដែរ។
- អាចទទួលសេចក្តីរាយការណ៍និងការពិភាក្សាអំពីល្មើសច្បាប់ការសិក្សាបច្ចេកទេសជំនាញរបស់ក្រុមត្រួតពិនិត្យនិងអ្នកអនុវត្តការសិក្សា។
- កម្មសិក្សាការីហ្វឹកហ្វឺនជំនាញទាំងអស់គ្នា មិនអាចធ្វើកិច្ចការសំអាតវិទ្យុសកម្មបានឡើយ។ បើសិនជាគេចង់ឱ្យឬបានឱ្យធ្វើកិច្ចការបែបនេះ សូមមកពិគ្រោះ។ លើសពីនេះ ក្នុងករណីដែលបានផ្លាស់ប្តូរទៅជំនាញពិសេស អាចឱ្យធ្វើកិច្ចការនេះបាន ដូច្នេះ ក្នុងករណីបែបនេះ ត្រូវសុំឱ្យស្ថាប័នបង្កើតកិច្ចសន្យាពន្យល់ឱ្យបានលំអិត។

妊娠・出産した場合に認められる主な権利

・【時間外労働、休日労働、深夜業の制限】
妊娠中及び出産後１年以内の女性は、時間外労働、休日労働、深夜業の免除を請求できます。変形労働時間制が取られる場合にも、１日及び１週間の法定労働時間を超えて労働しないことを請求できます。
・【軽易業務転換】
妊娠中は、他の軽易な業務への転換を請求できます。
・【産前休業】
出産予定日の６週間前（双子以上の場合は14週間前）から、請求すれば取得できます。出産当日は産前休業に含まれます。
・【産後休業】
出産日の翌日から８週間は、就業することができません。ただし、産後６週間を経過後に、本人が請求し、医師が支障がないと認めた業務には就業できます。
・【解雇制限】
産前・産後休業の期間及びその後30日間の解雇は禁止されています。
・【育児時間】
生後１年に達しない子を育てる女性は、１日２回各々少なくとも30分間の育児時間を請求できます。
・【母性健康管理】
妊婦健診を受けるための時間を確保することを請求できます。
妊婦健診を受け、医師等から指導を受けた場合は、指導事項を守ることができるようにするための必要な措置を申出・請求できます。
